


# វគ្គទី២

- ចាំះ .... ! គេធ្វើភូឈូយខេត្តណាលោកស្រី ប្អូនកូនខ្ញុំវាត្រឹមត្រូវណាស់ ស្រាក៏មិនចេះផឹក បារីក៏មិនចេះជក់ ហើយបើនិយាយពីរឿងស្រីញីវិញវាស្អប់ខ្ពើមជាទីបំផុត ។ ឆ្នាំក្រោយនេះឮថាបែបត្រូវផ្លាស់អោយមកនៅសៀមរាបផង កូនខ្ញុំមុខមាត់ស្អាតណាស់ រាងរៅក៏សមសួនជាអ្នកធំ បើនឹងនិយាយស្តីវិញអ្នកណាក៏គេកោតគោរពវាដែរ (លោកស្រីលិនថោងហូតយករូបថតកូនប្រុសមកបង្ហាញលោកស្រីពន្លក) ឃើញទេមុខមាត់វាសមជាអ្នកមានអំណាចណាស់ណាំ ......

លោកស្រីពន្លក យករូបកូនប្រសាក្នុងអនាគតមកពិនិត្យពិច័យយ៉ាងពេញចិត្ត ។ លោកស្រីសប្បាយណាស់ញញឹមបិទមាត់មិនជិតទេ គិតឃើញថា សោភិនីមានសំណាងល្អមែន ។ បន្តិចទៀត សោភិនីនឹងមានគេហៅលោកស្រីភូឈូយខេត្ត ចំណែករូបលោកស្រីវិញ ក៏នឹងបានឡើងឋានៈជាម្តាយក្មេកលោកភូឈូយខេត្តដែរ ។ លោកស្រីហុចរូបថតទៅប្តី ហើយបែរមកនិយាយជាមួយលោកស្រីលិនថោងថា ÷

- អា ........ បើឥចឹង លោកស្រីអញ្ជើញទៅភ្នំពេញវិញ ប្រញាប់លើកជំនូនភ្ជាប់ពាក្យអោយហើយទៅ បើបានជាសម្រេចថាព្រមអោយ ខ្ញុំមិនចង់បង្អែរបង្អង់អោយយឺតយ៉ាវតទៅទៀតទេ ។

- ចាំ កុំព្រួយលោកស្រី បានខាងណោះអោយឆាប់រហ័សខ្ញុំរិតតែអរខ្លាំងណាស់ទៅហើយ អាប្អូនកូនខ្ញុំម៉្ងៗ វារំអុកអោយតែខ្ញុំមកសៀមរាបសំរេចរឿងហ្នឹងទេតើ ! បើឥចឹង ខ្ញុំគិតថាសូមលាលោកស្រីត្រឡប់ទៅភ្នំពេញវិញឥឡូវហ្នឹង ។

Khmer Story Lovers

# ៦

# ឃ្លាតកាយណាយចិត្ត

ចិត្តស្រីប្រួលប្រែរដូចស្រល់ តាមខ្យល់កញ្ច្រោលបោកបក់បែន
ពាក្យស្បថពាក្យស្នេហ៍រាប់ម៉ឺនសែន លុះយកមែនទែនឥតបានការ ។
ឃ្លាតកាយណាយចិត្តគ្មាននឹកភ្នក ឱ្យប្រុសសោយសោកទ្រូងខ្លោចផ្សា
ស្រឹងមាសប្រាក់បាក់ក្រឡា ឆ្លុតកាមតណ្ហាសង្សារថ្មី ។

ចាប់តាំងពីថ្ងៃលើកជំនូនមក សោភិនីក៏អស់សេរីភាពនាងមិនអាចដើរទៅណាមកណាបានតាមអំពើចិត្តដូចជាពេលមុនទេ ម្ញ៉ៃៗ លាក់ខ្លួនពួនអាត្មានៅតែក្នុងផ្ទះ ។ បើមានការចង់ទៅផ្សារ ឬទៅលេងផ្ទះញាតិណាម្តងៗ តោងតែមានអ្នកដើរតាមជាអង្គរក្សគ្រប់ៗ ជំហ៊ាន ។

សោភិនី ឥឡូវកាន់តែស្គមដោយនាងព្រួយពេក ពេលយប់គេងមិនលក់ ពេលថ្ងៃញ៉ាំមិនបាន មិត្តកំសត់កម្ររបស់នាងដែលចិត្តស្មោះត្រង់ជាងគេក៏មានតែទឹកភ្នែកមួយមុខប៉ុណ្ណោះ គិតច្រើនយំច្រើន ។ ការទាក់ទងរវាងនាង និងណាស៊ីត្រូវឃ្លាតឆ្ងាយដាច់ស្រឡះ ជាងពីរខែមកហើយដែលនាងមិនបានជួបមុខប្រុសបណ្តូលចិត្តសូម្បីតែបន្តិចបន្តួច ។ អាការរោគប្លែកចេះតែកើតមានឡើងជារៀងរាល់ថ្ងៃ ដូចជាឈឺក្បាលវិលមុខ, ចង់ក្អួតចង្អោរ, ចង់ញ៉ាំម្ជូរ ។ សោភិនីនាងសង្ស័យនឹងនឹកភ័យណាស់ នាងបានទៅលួចសួរយាយ



ម៉មអ្នកធ្វើបាយ ដែលជាអ្នកជំនិតទំនុកទុកចិត្ត ទីបំផុតនាងក៏ដឹងថា ខ្លួននាងមានផ្ទៃពោះជាងមួយខែរួចទៅហើយ ភ័យណាស់ សោភិនីប្រញាប់សរសេរជាកូនសំបុត្រតូចមួយ ប្រើយាយម៉មឱ្យយកទៅប្រគល់ណាស៊ីមានសេចក្តីថា ÷

បងណាស៊ីបណ្តូលចិត្ត ...... !

ឥឡូវនេះអូនមានផ្ទៃពោះជាមួយបង ជាងមួយខែទៅហើយ សូមបងជួយគិតអូនផង តើយើងត្រូវធ្វើយ៉ាងម៉េច ណាមួយថ្ងៃរៀបការក៏កាន់តែកៀកមកហើយដែរ អូនសព្វថ្ងៃអត់ចេញទៅណាបានទេ សូមបងណាស៊ីអាណិតជួយដោះស្រាយអោយបានឆាប់ផង បើមិនដូច្នោះអូនដាច់ខ្យល់ស្លាប់ជាប្រាកដ

សូមតបមកវិញជាប្រញាប់

**ទេព-សោភិនី**

ណាស៊ី គ្រាន់តែបានទទួលសំបុត្រយកមកអានដឹងសេចក្តី គេរន្ធត់ក្នុងចិត្តស្ទើរប្រេះទ្រូងស្លាប់ ។ សោភិនីជិតការហើយមានផ្ទៃពោះ តើគិតជួយនាងម្តេចនឹងកើតគ្មានផ្លូវទេ ឱ ! វាសនាកូនក្នុងផ្ទៃជាតិនេះប្រហែលអ្នកធ្លាក់ក្នុងកណ្តាប់ដៃឪថ្មីទេដឹង ?

ក្នុងថ្ងៃនោះណាស៊ី ក៏សរសេរសំបុត្រមួយផ្ញើតាមយាយម៉មទៅសោភិនីវិញ មានសេចក្តីថា ÷

សោភិនីមាសបង ....... !

បងបានដឹងរឿងអូនអស់ហើយ បងជួយព្រួយនឹងអាណិតអូនណាស់ តែបងមិនដឹងជារកផ្លូវដោះស្រាយជួយអូនយ៉ាងម៉េចកើត បងគិតថា

នៅពេលជិតរៀបការយើងទាំងពីរនាក់ ត្រូវតែទៅសំពះបាទជើងលោកប៉ា លោកម៉ាក់អូន សារភាពជំរាបការណ៍ពិតឱ្យលោកដឹងថា យើងស្រលាញ់គ្នារហូតមានផ្ទៃពោះ កាលណាបើរឿងនេះគេដឹងឮឡើង លោកបូរិនក៏គេមុខជាមិនព្រមរៀបការជាមួយអូនទេ ឯលោកប៉ាលោកម៉ាក់អូន លោកមុខជាឃើញចិត្តយើងហើយអាណិតអាសូរលើកទោសឱ្យយើងទាំងពីរនាក់ពុំខាន ។

នេះជាគំនិតចុងក្រោយបំផុតរបស់បង បើអូនយល់ព្រម នៅពេលសល់ពីរបីថ្ងៃរៀបការ បងនឹងទៅសំពះបាទជើង សុំអភ័យទោសពីលោកប៉ា លោកម៉ាក់អូន ........ ។

## ឆ្លង- ណាស៊ី

គ្រាន់តែយាយម៉មចេញផុត ណាស៊ីក៏ដើរទៅប្រាសខ្លួនដេកសន្ទឹងសន្ទៃលើគ្រែទាំងទុក្ខព្រួយ ។

យុវជនអភ័ព្វស្នេហ៍ ដេករំពឹងគិតម្នាក់ឯងថា ក្នុងជីវិតនេះ ម្តេចក៏អភ័ព្វជាងគេម្ល៉េះ ព្រហ្មលិខិតចាំតែឆ្លៀតឱកាសទំលាក់ទុក្ខទោស ធ្វើទណ្ឌកម្មគេគ្រប់ពេល.វេលា ឪពុកស្លាប់. ម្តាយទីទ័លក្រ. រំពឹងទៅលើតែតិរះវិជ្ជាដែលខំសិក្សាមក ។ លុះមានសង្សារក៏ត្រូវគេមកពង្រាត់ចេញពីទ្រូងទៀតបើចេះតែមានរឿងទុក្ខសោកផ្ទួនៗ គ្នាដូច្នេះ ការសិក្សារបស់គេដែលកំពុងតែខំឱហាតរៀងរាល់ថ្ងៃ វានឹងក្លាយជាយ៉ាងម៉េចទៅវិញ ? ឱ ..... ! មធ្យមសិក្សាប័ត្រអើយ ឆ្នាំនេះឬក្នុងជាតិនេះប្រហែលជាខ្ញុំមិនបានយល់អ្នកទេមើលទៅ ........ ។



ពេលវេលាចេះតែធ្វើដំណើរទៅមុខឥតអាក់ យប់ហើយថ្ងៃៗ ហើយយប់ផ្លាស់វេនគ្នាជាលំដាប់រៀងទៅ ។ នៅសល់តែពីរខែទៀតទេ សោភិនីនាងនឹងត្រូវរៀបការហើយ ។

លោកភិរុណ ឃើញបុត្រីចេះតែសុបសៅស្គមទៅៗ លោកក៏នឹកព្រួយបារម្ភ ខ្លាចក្រែងសោភិនីធ្លាក់ខ្លួនមានជំងឺដំកាត់ នាំអោយខកដល់ពិធីរៀបមង្គលការ ។ ថ្ងៃមួយលោកក៏ផ្ញើសំបុត្រទៅលោកស្រីលិនថោងនៅភ្នំពេញអោយអញ្ជើញទៅលេងសៀមរាប ហើយបបួលលោកភូឈួយខេត្តបូរិនទៅជាមួយផង ដើម្បីអោយសោភិនី និងបូរិនបានទាក់ទងដើរលេងស្គាល់ចិត្តស្គាល់ថ្លើមគ្នារសាយពីក្តីទុក្ខ និងបំភ្លេសោភិនីអោយឆាប់ភ្លេចណាស៊ី ។

ដូច្នេះហើយ បានជាប្រាំថ្ងៃក្រោយពីលោកភិរុណផ្ញើសំបុត្រទៅភ្នំពេញ គេឃើញរថយន្តមែរសឺដេស 220 S ពណ៌ត្រួយចេកមកផ្ទះលោកម្តងទៀត ។

បូរិន មន្ត្រីកម្លោះរាងសង្ហាមែន ទាំងសំដីសំដៅឬកពាក៏ទន់ភ្លន់ហើយអង់អាច សមតាមពាក្យលោកស្រីលិនថោងអួតឥតខ្មោះ ។ ភូឈួយខេត្តកម្លោះព្យាយាមវាយខ្លួនអោយជិតសិទ្ធិនឹងសោភិនីជាទីបំផុត ។ លោកភិរុណបើកអំណាចអោយបូរិនបញ្ជិះឡានសោភិនីទៅណាមកណាបានតាមចិត្ត ។ ម្ល៉ោះហើយគេតែងឃើញបូរិននាំសោភិនីទៅអង្គរតូច. អង្គរធំ. បារាយណ៍ទឹកថ្លា និងកន្លែងសប្បាយផ្សេងៗ ទៀតជាច្រើន ។ តែ ....... ទោះជាយ៉ាងនេះក៏ដោយ សោភិនីពុំបានត្រេកត្រអាលសប្បាយរីករាយ ឬរាក់ទាក់តបនឹងបូរិនវិញទេ នាងអង្គុយក្នុងរថយន្តធ្មឹងឆ្មៃដូចរូបចម្លាក់ ទុកអោយបូរិននិយាយ

ប្រាជ្ញព្រោកឆ្កាដៃជើងដូចមនុស្សឆ្កួតតែម្នាក់ឯង ។ សោភិនីនាងកំពុងបង្វើរវិញ្ញាណ ទៅរកណាស៊ីទេវបុត្រស្នេហារបស់នាងតែមួយឯណោះ នាងបន់ឱ្យជិតដល់ថ្ងៃរៀបការ នាងនឹងអាលទំលាយការពិតប្រាប់ទៅឪពុកម្តាយនាង និងឪពុកម្តាយបូរិនអោយដឹងខ្លួន ។

លោកស្រីលិនថោងឃើញកូនកម្លោះ និងកូនក្រមុំបែបមិនសូវចុះសម្រុងគ្នា លោកស្រីក៏សុំអនុញ្ញាតពីលោកភិរុណ អោយបូរិននាំសោភិនីទៅលេងកំពត. កែប. ក្រុងព្រះសីហនុទៀត ។

ប៉ុន្មានថ្ងៃក្រោយមក មែរសីដេស (Mercedès 220 S) ក៏បោលកាត់ផ្សៃងធូលីនាំសោភិនីចេញផុតពីសៀមរាប ឆ្ពោះទៅក្រុងព្រះសីហនុ. កំពត. កែប តាមចំណង់ម្ចាស់របស់វា ។

តាមទស្សនវិទូផ្នែកវិទ្យាសាស្ត្រ ថាផែនដីយើងវិលពិតជាត្រូវមែន ចំណែកចិត្តមនុស្សលោកក៏វិលវល់ រកជឿយកប្រាកដទាត់ទៀងមិនបានដែរ។ យ៉ាងណាមិញ សោភិនីដែលជានារីម្នាក់ មានចិត្តស្មោះត្រង់ប្តូរផ្តាច់ចំពោះណាស៊ីជាគូសង្សារកំសត់កម្រតាំងពីដើមទីមក ឥឡូវដោយបូរិននាំដើរលេងនិយាយបញ្ចុះបញ្ចូលចាយវាយប្រាក់កាសហ៊ឺហាគ្មានញញើតដៃ សប្បាយចិត្តនិងជិះឡានថ្មីយកខ្យល់ពេលល្ងាចត្រជាក់ ។ ដឹកនាំបង្វក់ខួរក្បាលនាងអោយត្រលប់ធាតុ យល់តែការសប្បាយ ហ៊ឺហា. ផឹកស្រាបារាំង. ជក់បារី. រៀនរាំ ។ ចូលចិត្តកាត់សំពត់អាវណាស្តើង១ ស្តើរតែមើលសាច់ខាងក្នុងឃើញទាំងអស់ដំណើរដែលធ្លាប់តែដើរសក្តិសម ក៏រៀនពាក់ស្បែកជើងកែងចោតមួយតឹកដើរទើសទាសងរមុខងរក្រោយ ដូចមនុស្សដំបៅលេច ។ នេះហើយឬការ



ស៊ីវិល័យរបស់អ្នកទីក្រុង ?

មិនយូរប៉ុន្មាន អារ្យធម៌ទីក្រុងក៏ស្រោបដួងវិញ្ញាណរបស់សោភិនីជិតអស់ នាងលែងនឹកនាណាស៊ីហើយ សូម្បីសៀមរាបក៏នាងចង់ភ្លេចដែរ ដែលនាងចាំច្បាស់ក៏មានតែបូរិនកំពូលដួងចិត្តរបស់នាងមួយប៉ុណ្ណោះ នាងនឹកសរសើរវាសនានាងថាខ្ពស់មែនចេះបានមកជួបនឹងបូរិន កុំអីនាងមុខជាត្រូវខកខ្លួននឹងណាស៊ីជាមិនខាន បូរិនរបស់នាងស្អាតណាស់ គេចេះពោលពាក្យស្នេហាយ៉ាងផ្អែមត្រជាក់ ក្លិនគេក៏ក្រអូបឈ្ងុយឈ្ងប់ប្រស់ព្រំទៅដោយទឹកអប់ធុនថ្លៃ១ មិនធំញើសឆ្អេះឆ្អាបដូចជាណាស៊ីទេ បាតដៃគេក៏ទន់ល្មើយស្ទាបប៉ះត្រង់ណាក៏ចេះតែអោយស្រើបស្រាល ចង់តែធ្មេចភ្នែក ពេលគេងក៏គេជួយដោះអាវឱ្យ ជួនកាលគេជួយទាំងដោះអាអាវទ្រនាប់រនែតាទៅទៀត ។ មិនដូចជាណាស៊ីល្ងង់ណាស់មិនចេះស្ទាប. មិនចេះថ្នាក់ថ្នម. មិនចេះដោះអាវឱ្យ ពោលសរុបសេចក្តីបុរសក្នុងលោក សោភិនីចាត់ទុកថា ចាញ់បូរិនរបស់នាងទាំងអស់ ។

ឱហ្ន៎ ........ ចិត្តស្រីវេដូចចុងស្រល់ តើក្នុងលោកមានស្រីរបៀបសោភិនីប៉ុន្មាននាក់ ? ហើយស្រីចិត្តសាវ៉ារបៀបសោភិនីនេះ អោយឈ្មោះអ្វីសម ? ច្រើនឈ្មោះណាស់ បើតាមតែកំហឹងយើងចង់ដាក់អោយ ស្រីកាកី ! ស្រីមេអំបៅ ! ស្រីចិត្តចើក ! ស្រីសាវ៉ា ! ស្រីក្ងោកមាស ! ។ល។

នៅលើសណ្ឋាគារក្រុងកែប សោភិនីពាក់អាវវែងនីឡុងស្តើងមើលឃើញសាច់ខាងក្នុង (សំលៀកបំពាក់នេះគេសំរាប់ពាក់ដេកយប់គឺមានតែអាវស្តើងហើយស្រុងដល់កែងជើងអត់សំពត់ទេ) ដេកគងអន្ទាក់ខ្នា បង្ហុយបារី

បញ្ចេញសាច់ភ្លៅសស្គុះដូចត្រយូងចេកមកខាងក្រៅ ។ ពេលនោះបូរិនដើរចូលមក លោកស្រីលិនថោងដឹងអធ្យាស្រ័យកូនកម្លោះគាត់ណាស់ គាត់ស្ទុះចេញទៅក្រៅហើយទាញទ្វារផ្ទិបជិតមកវិញ ។

- បងទើបនឹងមកពីផ្សារឬ ?

សោភិនីសួរ កាលបើឃើញបូរិនមកអង្គុយផ្ទាស់សារុងជិតនាង ។

- ត្រូវហើយអូន បងទើបនឹងមកពីផ្សារ ចាំថ្ងៃក្តៅបន្តិចយើងនាំគ្នាទៅងូតទឹកសមុទ្រទៀតណា ។

- ចាំ ..... បង ...... ។

បូរិនមាត់តែនិយាយ ភ្នែកខំសម្លឹងមើលសាច់ភ្លៅសស្គុះរបស់សោភិនីស្ទើរលៀនគ្រាប់ភ្នែក គេគ្រីត ! គេស្រេវទឹកមាត់ ! ដូចយើងឃើញគេស៊ីអំពិលខ្ចីឥចឹង ។ មិនចាំបាច់ទេមទោមអោយយូរការ បូរិនក៏ប្រាសខ្លួនដេកជិតសោភិនីយកដៃត្រកងបីប្រាណដ៏ល្វតល្វៃមកឱបរឹត យ៉ាងក្រហល់ក្រហាយដូចសុនខដាច់សង្វែងហើយពើបប្រទះនឹងត្រពាំងទឹកថ្លាខ្យង ។

ពេលនេះ គេកំពុងកាន់ដៃគ្នាទៅស្ថានសួគ៌ហើយ គេសើច. គេប្រឡែង. គេឱបរឹតយ៉ាងគ្មានកោតក្រែង ឬខ្មាសអៀនអ្នកណាទាំងអស់ ។រីឯលោកស្រីលិនថោង ឈរទំពារស្លាផ្ទាច់ៗ នៅខាងមុខបន្ទប់រង់ចាំពេលវេលាគេនឹងបើកទ្វារអោយគាត់ចូលទៅវិញ ។

# ៧

# ភ្លេចបងហើយឬអូន ?

ផែនជីវិតរលំពុលគំនិត ស្រស់ស្រីបែកចិត្តព្រមរៀបការ
ភ្លេចភ្លាំងវិញ្ញាណឃ្លានតណ្ហា ចិត្តថ្លៃសារ៉ាឬស្បាក្រៃ ។
សោភិនីភ្លេចបងហើយឬអូន ទ្រូងរៀមស្រពោនសូន្យស្ទើរក្ស័យ
ដូចយកកាំបិតមកប្រល័យ ចាក់ចំហឫទ័យអោយមរណា ។

សោភិនី បានមកដល់សៀមរាបវិញហើយ ។ លោកភិរុណ និងលោកស្រីពន្លកត្រេកអរណាស់ ដោយដឹងថាកូនលោកផ្លាស់ចិត្តគំនិតបែរមកស្រុះស្រួលព្រមស្រលាញ់បូរិន ។

នៅតែ ៧ ថ្ងៃទៀតទេ នឹងដល់ថ្ងៃចូលរោងអាវាហ៍វិវាហ៍មង្គល ។ មុខផ្ទះលោកភិរុណ ពួកអ្នកបំរើស្រីប្រុស និងញាតិអ្នកស្រុកជិតខាង កំពុងជួយគ្នាសង់រោងការយ៉ាងប្រញឹកដៃ ។ ដំណឹងអាពាហ៍ពិពាហ៍រវាងលោកភូ-ឈួយខេត្តបូរិន និងកញ្ញាសោភិនីក៏ឮសុសសាយពេញទាំងក្រុងសៀមរាប ។

គួរអាណិតណាស៊ុណាស់ គេគ្រាន់តែបានដំណឹងថា មួយអាទិត្យទៀតសោភិនីរៀបការ ប្រុសកម្លោះងងឹតមុខឈរចង់ដួលទាំងជំហរ ភ័យណាស់ ! ស្តាយណាស់ ! ខ្លាចបានសោភិនីទៅគេ ។ ណាស៊ុរៀនលែងចូលគិតលែងឃើញជីវិណ ចិត្តគេនឹកមមៃរកតែសោភិនីមួយយ៉ាង ហើយគេក៏ក្លាយ

ទៅជាមនុស្សខូចចិត្តភ្លីភ្លើ និយាយច្រើនភ្លេចមុខភ្លេចក្រោយ ។

មួយថ្ងៃ ....... ពីរថ្ងៃ ....... រហូតនៅសល់តែបីថ្ងៃទៀតត្រូវរៀបការក៏មិនទាន់ឃើញស្រមោលនាងសោភិនី ឬសំបុត្រស្នាមអ្វីមកអោយដំណឹងគេបន្តិចសោះ ។ ណាស៊ីចេះតែអង្គុយចាំមើលផ្លូវតូសង្សារ គេមិនបានដឹងថាសង្សារគេកំពុងឈ្លក់វង្វេងនឹងប្រុសថ្មី បំភ្លេចរូបគេចោលឡើយ ។

ល្ងាចមួយ ណាស៊ីក៏សំរេចចិត្តស្កាត់ទៅជួបសោភិនី ។ គេទ្រាំលែងបានហើយ ពេលនេះទោះជាអ្នកណាយកទៅកាប់សម្លាប់ ក៏ត្រូវតែទៅជួបសោភិនីមួយភ្លែតសិនដែរ ។ ទៅដល់ក្បែរផ្ទះក្រឡេកឃើញរោងការ ណាស៊ីស្លុតចិត្តចង់រកកលខ្យល់ចាប់ ភ្នែកខំរេរំពៃគយគន់រកសោភិនី តែ ...... មិនឃើញនាងសោះ ។ ឱ ........ សោភិនីអើយ អូននៅឯណាទៅ តើអូនដឹងថាបងមករកអូនឬទេ ? ម្តេចក៏បាត់ស្ងាត់ស្ងៀមមិនឃើញអូនដូច្នេះ ឬក៏អូនកំពុងកើតទុក្ខយំសោកនឹកមកបង កុំកើតទុក្ខពេកសោភិនីអូន ! បើពិតជាគូព្រេងយើងគង់មិនព្រាត់គ្នាឡើយ ! បងមិនបោះបង់អូនទេ ពាក្យសម្បថ និងអនុស្សាវរីយ៍ទាំងប៉ុន្មានបងនៅចាំជានិច្ច ........ ! ឥឡូវបងកំពុងមករកអូនដើម្បីយើងទាំងពីរនាក់ទៅសំពះបាតជើងលោកប៉ាលោកម៉ាក់ ជំរាបការពិតអោយលោកបានជ្រាប ។

ណាស៊ីកំពុងឈរគិតភ្លេចខ្លួនក្បែររបងផ្ទះលោកភិរុណ ។ រថយន្តម៉ែរស៊ីដេស 220 S មិនដឹងជាមកពីកន្លែងណា ក៏ស្រាប់តែបត់វេវកាត់មុខណាស៊ី ។ សោភិនីនាងឃើញដែរ តែនាងបែរមុខចេញធ្វើជាមិនឃើញ ។ ស្រីកាកីកាន់ដៃលោកបូរិនឡើងជណ្តើរទៅខាងលើផ្ទះធ្វើព្រងើយ ។



ណាស៊ីកម្លោះកំព្រាបេះដូង ខំអើតមើលតាមគេទាល់តែគេបណ្តើរគ្នាឡើងទៅខាងលើផ្ទះបាត់ ។ ឆ្ងល់ណាស់ហេតុអ្វីបានជាសោភិនីមិនមើលមកគេ ឬមួយនាងមិនឃើញ ......... ឬមួយនាងភ្លេចរូបគេទៅហើយ ? ឈរចាំទាល់តែព្រលប់ងងឹត មិនឃើញសោភិនីចុះមក ណាស៊ីក៏ដើរត្រឡប់ទៅផ្ទះវិញ ។

ព្រឹកស្អែកឡើង ណាស៊ីក៏មកឈរចាំជួបសោភិនីនៅកន្លែងដដែលទៀត ភ្នែកខំប្រឹងសម្លឹងមើលទៅលើផ្ទះស្ទើរមិនពព្រិច ឈរចាំរោយជើងហើយក៏ចេះតែចាំតទៅទៀត ទាល់តែថ្ងៃជិតត្រង់ទើបគេភ្ញាក់ព្រើតដោយឃើញសោភិនីដើរចុះពីលើផ្ទះ ហើយមានកាន់ក្រណាត់ព្រែមួយដុំធំ ទំនងជាទៅកាត់សំពត់អាវ ។ ណាស៊ីត្រេកអរណាស់ប្រញាប់ស្ទូតដំណើរតាម ទៅដល់ជិតគេក៏ស្រែកហៅនាងពីក្រោយ ÷

- សោភិនីអូន ........ !

ស្រស់ស្រីបែរខ្វាប់មករកអ្នកហៅ លុះឃើញណាស៊ីហើយ ទឹកមុខដែលញញឹមអម្បាញមិញក៏ប្រែជាក្រញូវមួយរំពេច ។

- បងណាស៊ីទេឬ បងមកនេះមានការអ្វីទៀត ?

សោភិនីនិយាយទៅកាន់ណាស៊ីធ្វើឈើយ ហាក់ដូចជាមនុស្សមិនធ្លាប់ទាក់ទងគ្នាពីមុនសោះ ។

ណាស៊ីឆ្អែតណែនក្នុងដើមទ្រូង គេមិនចាប់ភ្លឹកថានឹងបានឮពាក្យដូច្នេះពីមាត់សោភិនីទេ ខ្លួនប្រាណទាំងមូលញាប់ញ័ររន្ធត់ តែគេខំសង្កត់ចិត្តស្តីទៅសោភិនីវិញ ÷

- សោភិនី ...... ! ម្តេចក៏ឆាប់ភ្លេចបងម្ល៉េះអូន ...... អូនមិនស្គាល់

ណាស៊ីទេឬ ? ណាស៊ីនេះហើយ ដែលស្រលាញ់ស្មោះត្រង់នឹងអូន ហើយណាស៊ីនេះទៀត ដែលអូនធ្លាប់និយាយថា នឹងស្មោះត្រង់ប្ដូរផ្ដាច់ សុខចិត្តស្លាប់រស់ជាមួយគ្នា ទោះជាមានឧបសគ្គមករារាំងយ៉ាងណាក៏ដោយ ចុះឥឡូវ ...... ពាក្យពិតទាំងនេះវាបាត់ទៅឯណាអស់ហើយ ......! សម្បថនៅលើខ្នងភ្នំ នៅក្រោមដើមពោធិ៍មុខខ្ទមអ្នកតា វាប្រែជាគ្មានន័យទៅវិញហើយឬ ? ឱ ...... សោភិនីអូន ចិត្តអូនម្ដេចក៏ឆាប់ប្រែប្រួល ងាយស្បថងាយភ្លេចទៅវិញម្ល៉េះ ..

សោភិនីឮពាក្យដំអូញ ប្រកបទៅដោយសោកសៀតដាក់ផ្ទៃផ្កាបស់ណាស៊ី នាងខឹងណាស់មុខឡើងក្រហមងាំង នាងនិយាយគំរោះគំរើយទៅដាក់ណាស៊ីវិញថា ÷

- ហ៊ឺះ ! បងទៅរើកកាយយករឿងយល់សប្ដិពីរាជណាមកនិយាយនេះ ខ្ញុំជាកូនត្រូវតែលុះដោយដំបូន្មានឪពុកម្ដាយ កាលមុនខ្ញុំនៅឆោតនៅល្ងង់ទើបបងបោកប្រាសខ្ញុំបាន ឥឡូវបងចង់មកបោកបញ្ឆោតទៀតឬ ? បងជាកូនសិស្សមានតិរិះវិជ្ជាខ្ពស់ គួរណាស់តែយកតិរិះវិជ្ជាដែលរៀនចេះដឹងទៅប្រកបជាមុខរបរចិញ្ចឹមជីវិតនៅក្រសួងណាមួយ មិនគប្បីយកតិរិះវិជ្ជាមកប្រលោមចិត្តកូនក្រមុំគេឥចឹងទេបង ។ រឿងអាក្រក់ដែលវាកន្លងហួសមកហើយ ខ្ញុំមិនប្រកាន់ទោសទេ ខ្ញុំគិតថាវាជាគ្រោះថ្នាក់ប្រចាំជីវិតរបស់ខ្ញុំទៅចុះ តែចាប់ពីពេលឥឡូវទៅ ចូរបងបើកផ្លូវអោយខ្ញុំមានសេរីភាព បានរៀបការដោយសប្បាយចិត្តផង សូមកុំមកតាមឆាឆៅផ្គួនាឈ្នានីសខ្ញុំតទៅទៀត ។

- ពិរោះណាស់សំដីអូន ! (ណាស៊ីនិយាយទាំងចុកចាប់) សំដីពិរោះផ្អែមល្ហែមប្រដូចទឹកឃ្មុំលាយជាតិពុលនេះហើយ ដែលធ្វើឱ្យបងភ្លេចកំណើតខ្លួន ! ភ្លេចការរៀនសូត្រ ! ភ្លេចអ្វីៗ ទាំងអស់នៅក្នុងលោក ! តែទីបំផុតបងក៏



ត្រូវជាប់ចោទថាជាអ្នកបោកប្រាសអូនទៅវិញ ហា ! ហា ! ហា ! ប្រសើរមែនសោភិនី ! ស្ត្រីរបៀបអូនក្នុងលោកមិនរកបានទេ ប្រវត្តិសាស្ត្រស្នេហា គេគង់តែនឹងចារឈ្មោះអូន ទុកក្នុងក្រាំងកាមទេពជាពិតប្រាកដ ហា ! ហា ! ហា !

ណាស៊ីពេលនេះមានកាយវិការមិនខុសពីមនុស្សវិកលចរិត គេសើច. គេពេប. ឈរជ្រែងចង្កេះនិយាយខ្លាំងៗ គ្មានខ្លាចអ្នកណាឮ ÷

- សោភិនីនារីរូបស្រស់ ! ក្នុងលោកគ្មានអ្នកណាស្រស់ឆើតឆាយដូចអូនទេ ទាំងសំដីក៏ស្រស់ ! រូបរាងក៏ស្រស់ ! សរុបសេចក្ដីទៅអ្វីៗក្នុងរូបអូនស្រស់ទាំងអស់ ! ហា ! ហា ! អ្នកដែលអាចយកមកផ្ទឹមនឹងសម្រស់អូនបានមានតែមួយគត់ គឺនាងកាកី !

ថាផុតមាត់ ដៃមួយក៏ចាប់ស្មាគេជាប់ ណាស៊ីងាកទៅក៏ឃើញប៉ូរិនគូដណ្ដឹងរបស់សោភិនី កំពុងមើលមកគេស្ទើរស៊ីសាច់ ។

- មានកើតរឿងអីឬអូននី ! ហើយអាគាត់នេះវាជាអ្នកណា ។

សោភិនីសើចចំអកអោយណាស៊ីបន្តិច ទើបនាងបែរនិយាយទៅលោកប៉ូរិន ÷

- ខ្ញុំមិនដែលស្គាល់ទេបង ! មិនដឹងមកពីណាផង ស្រាប់តែមកស្រែកឡូឡាដាក់ខ្ញុំ ...... !

សោភិនី និយាយមិនទាន់ផុត លោកភូឈ្មួយខេត្តប៉ូរិនក៏ដាល់មាំង ! ចំផ្ចាមណាស៊ី ហើយថែមមួយជើងចំឆ្អឹងជំនីលាន់ឮសូរអឿក ! បណ្ដាលអោយជនកំសត់ ដួលស្របប៉ាបក្រោកលែងរួច ។

- យើ ! អាក្របីព្រៃ (លោកប៉ូរិនឈរបោសដៃនិយាយស្រែកគំរាមទៅណាស៊ី) ឯងមកពីណាក៏ហ៊ានសំដីខែងម្ល៉េះ នេះជាប្រពន្ធរបស់អញ

ណា បើឯងចង់និយាយសំដីរបៀបនេះ ត្រូវឯងទៅរកកន្លែងនិយាយជាមួយស្រីផ្សេងទៀតទៅ ឬមួយក៏អាឯងឆ្កួត ? បើថាឆ្កួតអញនឹងដាក់ឡានបញ្ជូនទៅព្រែកថ្នោត ឆ្លើយ ..... !

លោកបូរិន ខាកស្តោះទឹកមាត់រួចដើរទៅកាន់សោភិនី ។ ពេលនោះមនុស្សម្នាក៏ផ្អើលឈូរឆរ មកចោមរោមព័ទ្ធកន្លែងកើតហេតុពេញមួយរំពេច ។

- ទៅផ្ទះវិញអូន កុំនៅឈរមើលអាចំកួតស្អីគេហ្នឹង ! បើចង់ទៅណាមកណាក្រោយប្រាប់បង១ នឹងជូនឡានទៅ ឈប់ដើរម្នាក់ឯងទៀតឮទេ ?

- ចាំះ បង ..... !

លោកបូរិន និងសោភិនី នាំគ្នាឡើងរថយន្តបើកចេញទៅបាត់ហើយ ពេលនោះខ្ញុំមកពីផ្សារឃើញគេឈរមើលអ៊ូអរក៏ចង់ដឹងដើរចូលមកមើល ។ លុះឃើញណាស៊ីបែកឈាមមាត់ ខ្ញុំភ័យណាស់ ! ស្ទុះទៅលើកគ្រាហ៍ដោយសួរទាំងតក់ស្លុតទៅគេ ÷

- យី ! ណាស៊ីឯងកើតអីហ្នឹង ? អ្នកណាគេធ្វើបាបមិត្តប្រាប់ខ្ញុំភ្លាមមក ! ប្រាប់ខ្ញុំអោយឆាប់មកណាស៊ី !

ណាស៊ីគ្រវីក្បាលព្រមទាំងឆ្លើយមកខ្ញុំវិញថា ÷

- កុំទាន់ចង់ដឹងអីសំណាង ចូរមិត្តជួយនាំខ្ញុំទៅផ្ទះសិន ។

ទាល់តែរិះខ្ញុំលែងហ៊ានសួរតទៅទៀត ក៏ជួយគ្រាហ៍ណាស៊ីដាក់រ៉ឺម៉កត្រឡប់ទៅផ្ទះវិញ ជាបន្ទាន់ក្នុងគ្រានោះ ។

# ៤

# អាពាហ៍ពិពាហ៍សង្សារខ្ញុំ

អាពាហ៍ពិពាហ៍សង្សារខ្ញុំ មេបាចាស់ទុំបាចផ្កាស្លា
អូនឱនក្រួញក្រាបសិរសា ភ្លេចអស់ស្នេហាគ្រាកំសត់ ។
ស្តាប់សូរភ្លេងកន្សែងក្រហម គេថ្នាក់គេថ្នមទីបំផុត
បងឈរភ្លេចភ្លាំងកាយស្រយុត អាសូរតែបុត្រក្នុងផ្ទៃអូន ។

បីថ្ងៃក្រោយមក ពិធីរៀបមង្គលការរវាងលោកបូរិន និងសោភិនីក៏មកដល់ ។ នៅមុខផ្ទះលោកភិរុណមានរៀបចំតុបតែងលំអទៅដោយស្លឹកដូងនិងដើមទន្សៃ ព័ទ្ធវង់ខ្វាត់ខ្វែងដូចរោងមហោស្រព ។ ឧត្បោសនស័ព្ទពីរចងលើចុងដូង បញ្ចេញសម្លេងភ្លេងការកន្សែងក្រហមឮរងំ ធ្វើអោយបេះដូងក្រមុំកម្លោះដែលមកជួយក្នុងពិធីមង្គលការលន្លង់លន្លោច ព្រឺព្រួចគ្រប់ៗ អាត្មាហើយលបលួចសម្លឹងមុខគ្នាទៅវិញទៅមក សង្ឃឹមញញឹមទុកក្នុងចិត្តតែរៀងខ្លួន ។

នៅលើផ្ទះធំ កូនក្រមុំ និងកូនកម្លោះ កំពុងក្រាបសំពះឱនក្បាលដល់ខ្នើយ ចាំស្តាប់លោកអាចារ្យរៀបចំផ្សំផ្គុំបាចផ្កាស្លា និងអោយពរតាមប្រពៃណី ។ ផុតពីលោកអាចារ្យមក អ្នកមហាមេបាចាស់ទុំទាំងសងខាងក៏ចូលចងខ្សែអំបោះក្រហម លើកដៃក្រមុំកម្លោះម្តងម្នាក់ជាសញ្ញាថា យល់

ព្រមទទួលស្គាល់អ្នកទាំងពីរជាប្តីប្រពន្ធចាប់តាំងពីពេលនេះទៅហើយ ។ លុះដល់ម៉ោង ៦ ល្ងាចទើបមានរៀបចំពិធីជប់លៀងភ្ញៀវ កូនកម្លោះកូនក្រមុំចេញមកហុចបារីម្តងទៀតជាសូវេចកិច្ច ។

នៅផ្ទះណាស៊ីងណោះ មីងមឿនអង្គុយបញ្ឈរក្បាលជង្គង់ ជូតទឹកភ្នែកអាណិតកូនប្រុសបណ្តូលចិត្តគាត់សឹងរលួយថ្លើមប្រមាត់ ។ ពីរបីថ្ងៃហើយណាស៊ីមិនព្រមស៊ីបាយទឹកសោះ សាលារៀនក៏គេមិនទៅ ម៉្ងៃៗ អង្គុយសំកុកនៅតែក្នុងបន្ទប់ ។ ជួនកាលគេយំ ផុតពីយំទៅជាសើច ។ ឱហ្ន៎ ...... ! សេចក្តីស្នេហាកាចសាហាវណាស់ វាធ្វើអោយមនុស្សចេះដឹងត្រឡប់ទៅជាឆ្កួតបានដោយងាយ យ៉ាងនេះទេតើ បានជាគេហាមផ្តាច់ចំពោះយុវជនយុវ-នារី ដែលកំពុងស្ថិតនៅក្នុងវ័យរៀនសូត្រមិនអោយមានស្នេហា តែមានហើយវាក៏មានទុក្ខ រៀនលែងចូល. ចិត្តរវើរវាយ. ដូចណាស៊ីជាតួយ៉ាង ។ គប្បីយុវជន យុវនារីទាំងឡាយចៀសវាងអោយផុតពីរណ្តៅជ្រោះស្នេហា ។

មីងមឿន ចូលទៅក្នុងបន្ទប់អង្គុយជិតកូន គាត់យកដៃស្ទាបក្បាលណាស៊ីស្រាលៗ ដោយសេចក្តីស្រលាញ់ និងអាណិត ។

- ខំកាត់ចិត្តខ្លះៗ ទៅកូន ប្រហែលជាគេមិនមែនជាគូនឹងយើងពីជាតិមុនទេ បានជាជាតិនេះយើងគ្មានសំណាងរួមវាសនានឹងគេដូច្នេះ ។

មីងមឿនឈប់ស្ងៀមបន្តិច គាត់ទាញជាយក្រមាពាក់លើស្មាយកមកជូតទឹកភ្នែក ដែលចេះតែហូរហៀរមក រួចហើយគាត់ក៏និយាយតទៅទៀត ÷

- ម៉ែបាននិយាយប្រាប់ឯងជាច្រើនដងហើយដែរ តែឯងមិនព្រម



ស្តាប់ពាក្យម៉ែសោះ យើងកើតមកក្នុងត្រកូលអ្នកក្រ កុំលោភលន់ចង់ផ្ញើវាសនានឹងអ្នកមានទ្រព្យសម្បត្តិពេក ......... ពូជក្អែកត្រូវទៅតាមហ្វូងក្អែក មិនអាចទៅនៅលាយឡំជាមួយហ្វូងហង្សបានទេ ...... ទីបំផុតនៃការជំនះចិត្ត វានាំមកនូវសេចក្តីអស់សង្ឃឹម កើតទុក្ខរីងរៃ ស្គាំងស្គមខ្លួនដូច្នេះឯង តែ ... កុំទាន់អស់សង្ឃឹមក្នុងជីវិតកូន ស្រ្តីរូបស្អាតរបៀបសោភិនីក្នុងលោកមិនមែនមានតែមួយទេ នៅមានសល់ច្រើនណាស់ ! កូនត្រូវខំរៀនវិញឡើង ដើម្បីប្រឡងយកមធ្យមសិក្សាប័ត្រ កុំអោយគេដៀលថាយើងខូចចិត្តប្រឡងធ្លាក់ព្រោះរឿងស្នេហា អនាគតខាងមុខនៅចាំទទួលយើងជានិច្ច ។

ទោះជាឮពាក្យម្តាយដាស់តឿន ហើយខ្លួនគេខំកាត់ចិត្តយ៉ាងណាក៏នៅតែបំភ្លេចរូបសោភិនីមិនបាន ។ គេនៅតែនឹកអាឡោះអាល័យ អនុស្សាវ-រីយ៍ចាស់ៗ វាចេះតែកញ្ជ្រោលផុសផុលក្នុងគំនិត អោយគេគិត អោយគេស្រមៃហាក់ដូចជានៅថ្មីៗ ក្លិនថ្ពាល់ក្រអូបប្រហើរ ពាក្យសម្បថដែលថានឹងស្រលាញ់តែគេមួយនាក់ក្នុងជាតិនេះ ចុះឥឡូវបាត់ទៅឯណាអស់ហើយ ។ អ្នកតាក្រោមដើមពោធិ៍ធ្លាប់ល្បីល្បាញខាងធ្វើអោយគេចុកពោះ ! ខាងទទួលពាក្យសម្បថ ! ឥឡូវម្តេចមិនឃើញមកជួយគេផង ម្តេចក៏មិនទៅកាច់កសោភិនីអោយស្លាប់បាត់ទៅ ទុកនាងអោយរស់នៅធ្វើអ្វីទៀត ។

ណាស៊ីដកដង្ហើមធំគេបែរមើលមុខម្តាយទាំងអណោចអធម្មក្នុងចិត្ត

- ឈប់យំទៅម៉ែ ...... ! កុំមកកើតទុក្ខនឹងខ្ញុំខ្លាំងពេក នេះជាកម្មរបស់ខ្ញុំទេ សោភិនីធ្វើអោយខ្ញុំផុតសង្ឃឹមគ្រប់យ៉ាងក្នុងជីវិត តែអកុសលណាស់ ! ខ្ញុំនៅតែបំភ្លេចនាងមិនបាន ខ្ញុំខ្មាសគេណាស់ម៉ែ ! ចង់តែស្លាប់អោយ

បាត់ពីលោកនេះទេ ! រស់ធ្វើអ្វីមិនដូចប្រុសគេឯង ....... ។

មោ៉ង ៦ ល្ងាចហើយ ........

នៅផ្ទះលោកភិរុណ ភ្ញៀវប្រុសស្រីកំពុងអញ្ជើញចូលមកជាបន្ទាប់បន្ទ រថយន្តតូចគ្រប់ម៉ាកគ្រប់ធុនចតរៀងរាយតាមមាត់ស្ទឹង ។ ឧគ្ស្បាសនស័ព្ទ បានបន្លឺបទចំរៀងសម័យដែលនិពន្ធឡើងដោយលោកពៅស៊ីផូ មានស៊ីនស៊ីសាមុត. នាងហួយមាស. នាងឈុនវណ្ណា. សុសម៉ាត់ជាអ្នកច្រៀងនោះ ឮសូរគ្រលួចពិរោះចាប់ចិត្តដល់ភ្ញៀវក្រៃលែង ។

ជុំវិញរោងជប់លៀង រំលេចទៅដោយអំពូលអគ្គិសនីតូចៗ និងអំពូលវែង (Type Neon) ឆ្លាស់ពណ៌ចំរុះ ស. លឿង. ខៀវ. ក្រហម ។ គេរាល់គ្នាសប្បាយណាស់ ម្នាក់ៗ ផឹកស្រាតែបីបួនកែវ ខ្លះយកចង្កឹះមកគោះដបធ្វើសង្វាក់តាមភ្លេង ខ្លះស្រវឹងខ្លាំង ក៏ក្រោកពីកន្លែងអង្គុយទៅលោតឡកចាក់ក្បាច់កណ្ដាលវង់ ក្រោមស្នូរទះដៃពីពពួកភ្ញៀវឯទៀតៗ ឮសូរប្រោះ ! ប្រោះ ! មិនដាច់រយៈ ។

នៅក្រោមដើមស្វាយប្របរបងខាងត្បូងផ្ទះ បុរសមួយរូបឈរអើតមើលនាយមើលអាយ ដូចជាចង់រកអ្នកណាម្នាក់ បុរសនេះគឺណាស៊ីហ្វីងឯង គេមកឈរក្រោមដើមស្វាយនេះយូរហើយ ដើម្បីចាំមើលកូនកម្លោះកូនក្រមុំចេញមកហុចបារីបំរើភ្ញៀវ ។

មួយសន្ទុះក្រោយមក គូស្វាមីភរិយាថ្មីក៏បណ្ដើរគ្នាចុះពីលើផ្ទះមកកាន់កន្លែងភ្ញៀវ ដោយមានស្ត្រីក្មេងៗ កំដរកូនក្រមុំពីរបីនាក់ទៀត កាន់ពានបារីដើរតាមក្រោយ ។ សោភិនីស្អាតណាស់ នាងតែងខ្លួនក្នុងឈុតសំលៀក-



បំពាក់រាត្រីពណ៌ស្វាយសក់បួងលាវរុំផ្កាម្លិះជាកម្រង ពួកភ្ញៀវលែងផឹកបែរមកមើលនាងស្រឡាំងកាំងគ្រប់គ្នា យី ! ស្អាតមែនវើយដូចទេពធីតាច្យុតមកពីឋានលើឥចឹង ភ្ញៀវម្នាក់និយាយឡើង ។

ណាស៊ី ខំសម្លឹងមើលអតីតសង្សារពីចម្ងាយ ទាំងដួងចិត្តក្រៀមស្រពោន ការសោកស្ដាយអាឡោះអាល័យ ក៏កន្ត្រាក់អារម្មណ៍គេអោយនឹកឃើញម្ដងទៀត គេឈរសម្លឹងគិតតែម្នាក់ឯងថា ឱ ...... សោភិនីអើយ អូននិងប្ដីអូនសមគ្នាណាស់ បុណ្យសក្តិគេក៏មាន ! ទ្រព្យសម្បត្តិគេក៏បរិបូណ៌ ..... ផ្ទុយស្រឡះពីបង ដែលគ្រាន់តែជាកូនអ្នកក្រ មានដួងចិត្តស្មោះត្រង់ប៉ុណ្ណោះ សូមបំរើអូនទល់ថ្ងៃស្លាប់ សោភិនី ........ ! អូននៅចាំសម្បថក្រោមដើមពោធិ៍ទេ ....... អនុស្សាវរីយ៍ក្នុងបន្ទប់អណ្ដូងព្រេងអង្គរធំ ក្រោមស្នូររន្ទះភ្លៀងផ្គរ ឥឡូវអូនភ្លេចហើយឬ ? មែន ! អូនគួរតែភ្លេច ព្រោះថ្ងៃនេះអូនបានគូថ្មីក្មេកកើយ បងមិនខឹងអូនទេ ពីព្រោះបងក្រមិនអាចរកសុភមង្គលអោយអូនបានគ្រប់គ្រាន់ទើបអូនបែរទៅរកគូថ្មី ...... សូមថែរក្សាគ្នាឱ្យសុខចុះសោភិនី តែ ....... អូនគួរអាសូរដល់កូនក្នុងផ្ទៃផង ពីថ្ងៃនេះទៅវាត្រូវបានឪថ្មីគេថែរក្សា គេថ្នាក់ថ្នម ចំណែកបងគ្មានវាសនានឹងទទួលខ្លួនធ្វើឪពុកទារកនេះទេ ។ ឱ ........ វាសនាមនុស្សលោក ម្ដេចក៏ឆាប់ប្រែប្រួលភ្លាមៗ ម៉្លេះ ? នេះហើយអាពាហ៍ពិពាហ៍សង្សារខ្ញុំ ....... !

ភ្ញៀវក្រោកដើរចេញពីតុត្រឡប់ទៅផ្ទះវិញខ្លះៗ ហើយសោភិនី និងប្ដីរនក៏ឡើងទៅលើផ្ទះផ្លាស់សំលៀកបំពាក់ដែរ ។ បន្ទាប់មកកន្លែងជប់លៀងក៏អស់ភ្ញៀវរលីង នៅសល់តែក្មេងផ្ទះបួនប្រាំនាក់កំពុងសប្បាយនឹងម្ហូបសល់

លើតុនាំគ្នាស៊ីផឹកកំដរបរិយាកាសតទៅទៀត ។

ណាស៊ី ឈានជើងចេញពីផ្ទះលោកភិរុណ ដើរត្រើស១ តាំងពីភូមិវត្តស្វាយរហូតដល់ផ្ទះ ។

រាត្រីនេះ ជារាត្រីសោកាបំផុតក្នុងជីវិតរបស់គេ ។ យុវជនកំសត់ដេកបង្ហូរជលនេត្រ ដក់ដាមទៅដោយសេចក្តីព្រួយ និងក្តៅក្រហាយក្នុងដួងកមល ដូចភ្លើងកល្បប្រល័យជីព ។

# ៩

# ប្រឡងធ្លាក់តាំងចិត្តបួស

ខូចចិត្តផ្អិតផ្ទូងក្រំឱរា　　ដើរលេងផឹកស្រាឥតបើគិត
កិច្ចការរៀនសូត្រលែងប្រព្រឹត្ត　　លង់លើយគំនិតកាមតណ្ហា ។
លុះថ្ងៃប្រឡងក៏ធ្លាក់ទៀត　　ទ្រូងរីងចង្អៀតរិតខ្លោចផ្សា
តាំងចិត្តសាងផ្នួសបួសសាសនា　　ឱ ! អើយអនិច្ចាមិនសំរេច ។

រៀបការបានបួនថ្ងៃ លោកភូឈួយខេត្តបូរិនក៏នាំសោភិនីទៅនៅផ្ទះរបស់លោកឯខេត្ត ....... ។ ណាស៊ីឥឡូវខុសពី ណាស៊ីមុនឆ្ងាយណាស់ ការរៀនសូត្ររបស់គេចេះតែឱនថយចុះមកជាលំដាប់ គេក្លាយខ្លួនទៅជាមនុស្សប្រព្រឹត្តអំពើអបាយមុខ ចេះជក់បារី, ផឹកស្រា, រាំរែក, ដើរលេងទើស១ភ្លឺ ជារៀងរាល់យប់ ។

ខ្ញុំនិងមីងមឿន ខំនិយាយលួងលោមដាស់តឿន រិះរកមធ្យោបាយគ្រប់បែប ដើម្បីទាញសតិអារម្មណ៍អោយបែរមកចូលក្នុងការរៀនសូត្រ តែណាស៊ីគ្រវីក្បាលរាដៃ បែរជាមកគំហកកំហែងអោយខ្ញុំទៅវិញ ។

- សំណាងឯងមិនចាំបាច់មកប្រដៅខ្ញុំទេ ...... ! យើងអាយុក៏ស្របាលគ្នា ថ្នាក់រៀនក៏ប៉ុនគ្នា ខួរក្បាលចេះត្រិះរិះក៏ប្រហែល១ គ្នា ដូច្នេះមិនចាំបាច់មកទូន្មានខ្ញុំទេ ! ខ្ញុំសូមអរគុណជាពន្លឺកដែលសំណាងឯងចេះជួយឈឺ

ឆ្អាលនឹងខ្ញុំ ។

ណាស៊ីនិយាយធ្វើព្រងើយ រួចគេក៏លើកកែវស្រាផឹកតទៅទៀត ខណៈពេលដែលខ្ញុំបានទៅជួបគេនៅក្នុងបារ ។ ខ្ញុំអត់ខឹងនឹងពាក្យអសុរសរបស់ណាស៊ីទេ ផ្ទុយទៅវិញ ខ្ញុំកាន់តែអាណិតគេខ្លាំងណាស់ទៅទៀត ព្រោះខ្ញុំយល់ច្បាស់ហើយថា ណាស៊ីកំពុងខូចចិត្តក្នុងរឿងវិបត្តិស្នេហា ។

- ណាស៊ី (ខ្ញុំហៅឈ្មោះគេព្រមទាំងលើកដៃទះស្មាតិច១) ខ្ញុំមិនមែនចង់អួតអាងថាខ្ញុំចេះដឹងជាងណាស៊ីឯងទេ តែថា ....... ពេលវេលាប្រឡងរបស់យើងនៅសល់តែបីខែទៀតប៉ុណ្ណោះ បើមិត្តរវល់តែខូចចិត្ត ដើរលេងរាំរែកផឹកស្រា ទើស១ ភ្លីដូច្នេះ សុខភាពរបស់មិត្តនឹងត្រូវទ្រុឌទ្រោម ជួនកាលក៏អាចបណ្តាលឱ្យទៅជាធ្លាក់ខ្លួនឈឺធ្ងន់ក៏សឹងថាបាន អ្នកមីងនៅផ្ទះឯណោះគាត់អង្គុយយំចាំមើលផ្លូវមិត្តរាល់យប់ ....... គាត់ព្រួយចិត្តណាស់ដោយឃើញកូនលះបង់ការសិក្សាដែលជាពន្លកសង្ឃឹមរបស់គាត់តែមួយក្នុងជីវិត ។

ណាស៊ីដូចជាស្តាប់ពាក្យខ្ញុំបានមួយខណៈ កែវស្រាដែលហៀបនឹងលើកក្រេបទៅក្នុងមាត់ ក៏កាន់ទ្រឹងឈប់ស្ងៀម ។ ដោយសារពន្លឺភ្លើងអំពូលពណ៌ចាំងភ្លឺបភ្លែត១ ខ្ញុំមើលឃើញណាស៊ីធ្វើមុខក្រៀម ហើយមានទឹកថ្លា១ហូរចេញពីរង្វង់ភ្នែកគេ ។ ខ្ញុំដឹងថាណាស៊ីយំ ប្រហែលជាគេភ្ញាក់ខ្លួនឡើងវិញហើយមើលទៅ ខ្ញុំក៏និយាយដាស់តឿនគេថែមទៀត ÷

- ស្រ្តីក្នុងលោកមិនមែនមានតែសោភិនីមួយឯណា ចំពោះស្រ្តីរូបល្អចិត្តក្បត់ដូច្នេះ តើមិត្តនៅអាឡោះអាល័យធ្វើអ្វី ? បើគេស្រលាញ់យើង គេមិនមែនទៅរៀបការជាមួយប្រុសដទៃទេ ....... ខំរៀនទៅមិត្ត យើងជាយុវ-



ជនត្រូវមានចិត្តក្លាហាន អនាគតយើងជាសសរទ្រទ្រង់នៃប្រទេសជាតិ យើងខូចចិត្តព្រោះរឿងស្នេហាវាអាម៉ាសមុខណាស់ កុំអោយយុវជនជាន់ក្រោយគេយកតម្រាប់តាម ! កុំអោយស្លាប់ទៅមានឈ្មោះថាយើងជាអ្នកនាំឱ្យយុវជនទាំងប្រទេសត្រូវខូចកិត្តិយសដោយសារតែរូបយើងម្នាក់ ..... !

ណាស៊ីដាក់កែវស្រាចុះ បែរមើលមុខខ្ញុំដោយខ្សែភ្នែកទ្រង់អង្វរសារភាពទទួលខុស គេទាញកូនកន្សែងពីក្នុងហោប៉ៅមកជូតទឹកភ្នែកហើយនិយាយសម្លេងអួល១ រកខ្ញុំ ÷

- ខ្ញុំខុសហួសហើយសំណាង ....... ! ខ្ញុំជាមនុស្សចាញ់ធម្មជាតិ ! ជាយុវជនកំសាក ........ យុវជនទូទៅគួរកុំយកតម្រាប់តាមខ្ញុំ ..... គួរស្អប់ខ្ពើមខ្ញុំអោយច្រើនជាទីបំផុត ពីព្រោះចិត្តខ្ញុំជាកញ្ជះនៃសេចក្តីស្នេហា ខ្ញុំធ្វើអោយម្តាយត្រូវកើតទុក្ខរីងរៃ ស្គាល់តែទឹកភ្នែកគ្រប់ពេលវេលា .......

ណាស៊ីទាញដៃខ្ញុំយកទៅច្របាច់យ៉ាងណែន ចក្ខុគេទាំងទ្វេដិតដាមទៅដោយទឹកភ្នែក គេសម្លឹងមើលមុខខ្ញុំ ហាក់ដូចជាចង់រកការពិតអ្វីម្យ៉ាងបន្តិចមកគេក៏និយាយឡើង ÷

- សំណាងមិត្តល្អនឹងខ្ញុំណាស់ .... ! ក្នុងចំណោមមិត្តភក្តិទាំងអស់មានតែសំណាងឯងទេចិត្តស្មោះត្រង់នឹងខ្ញុំ ..... ស្រលាញ់ខ្ញុំ ....... ! ហើយចេះជួយប្រលោមលួងលោមចិត្តខ្ញុំក្នុងគ្រាកំពុងមានទុក្ខ ។ ចាប់ពីព្រឹកស្អែកទៅខ្ញុំត្រូវតែខំរៀនតាមមិត្តហើយ សោភិនី ..... នាងមានប្តីថ្មី ខ្ញុំមិនជាសោកស្តាយ ឬអាឡោះអាល័យអ្វីទេ តែ ........ ខ្ញុំនឹកតូចចិត្ត ! ស្មានមិនត្រូវនូវជម្រៅចិត្តស្រី ដែលប៉ិនភូតភរបោកប្រាស អោយខ្ញុំលង់ទៅក្នុងភពថ្មីមួយពី

ពិភពស្នេហា ឱ .....! ពាក្យសម្បថរបស់ស្ត្រី តើវាមានន័យអ្វីខ្លះសម្រាប់បុរស ? គ្មានទាល់តែសោះ ! ពាក្យសម្បថរបស់ស្ត្រីក៏គឺការបោកប្រាសប្រុសៗមួយគ្រាប៉ុណ្ណោះឯង រួចហើយនាងក៏បំភ្លេចវាទៅវិញអស់រលីង ..... ទឹកហូរមិនចេះហត់ប្រុសស្បថកុំអោយជឿ ខ្ញុំមិនចង់អោយគេនិយាយពាក្យនេះទៀតទេ សំណាង ខ្ញុំចង់លុបពាក្យបូរាណកាលចាស់គំរិលនេះចោលហើយដាក់ពាក្យថ្មីជំនួសវិញថា ទឹកហូរមិនចេះហត់ ពាក្យស្រីស្បថ គឺក្បត់ប្រុសហើយ !

- ណាស៊ីនិយាយចប់ ក៏ឱនមុខយកដៃគងថ្ងាសជ្រប់លើតុ ពិសពុលនៃសុរាកំពុងបញ្ចេញថាមពលពាសពេញខ្លួនគេ ។ ខ្ញុំដឹងថាណាស៊ីស្រវឹងស្រាខ្លាំង ខ្ញុំក៏ចេញទៅក្រៅហៅរ៉ឺម៉ក ហើយជួយគ្រាហ៍ជូនត្រឡប់ទៅផ្ទះវិញ ។

បីខែក្រោយមកទៀត ការប្រឡងមធ្យមសិក្សាប័ត្រក៏មកដល់ ។

សិស្សគ្រប់រូបប្រុងប្រៀបរៀបចំខ្លួន ធ្វើដំណើរមកភ្នំពេញមុនថ្ងៃប្រឡងចំនួនមួយអាទិត្យ ។ ខ្ញុំ និងណាស៊ី ក៏បានធ្វើដំណើរមកជាមួយនឹងគេឯងដែរ ។

មកដល់ភ្នំពេញ ខ្ញុំ និងណាស៊ីបបួលគ្នាទៅសំណាក់នៅផ្ទះវង្សវិទ្ធិឯង ។ ព្រឹកថ្ងៃមួយក្រោយដែលវង្សវិទ្ធិឯងទៅធ្វើការបាត់ទៅ ខ្ញុំ និងណាស៊ីនឹកអផ្សុក យើងទាំងពីរនាក់នាំគ្នាដើរទៅលេងផ្សារ ដើម្បីអោយបានលំហែកាយ និងប្រយោជន៍រកទិញប្រដាប់ប្រដាសិក្សាខ្លះៗ ។

ណាស៊ី គេសប្បាយចិត្តណាស់ គេឆ្លងកាត់ពីវិថីមួយទៅវិថីមួយភ្លែករំពៃគយគន់មើលទេសភាពទីក្រុង ដែលរីកចំរើនយ៉ាងឆាប់រហ័ស ។ គេនឹកកោតសរសើរដល់ថ្វីដៃរាជការក្រុងក្នុងសម័យសង្គមរាស្ត្រនិយម ដែលប៊ិន



ប្រសប់រៀបចំលំអទីក្រុងភ្នំពេញ ឱ្យក្លាយទៅជាស្ថានសួគ៌មួយសំរាប់ប្រជាជនខ្មែរ និងជាទីត្រេកត្រអាលនៃជនទេសចរគ្រប់សញ្ជាតិ ។

ណាស៊ី ដើរបណ្ដែតអារម្មណ៍ដល់កាច់ជ្រុងរោងភាពយន្តកាពីតូល ពេលនោះស្រាប់តែគេទុចដំណើរ ហើយភ្ញាក់ព្រើតបូរិន និងសោភិនីដែលគេខំបំភ្លេច នឹងមិននឹកស្មានថា បានជួបទៀត ក៏ស្រាប់តែឃើញអ្នកទាំងពីរដើរចេញពីភោជនីយដ្ឋាន ថៃសានមក ។

ណាស៊ី ចាប់ដៃខ្ញុំជាប់ដើរទៅមុខលែងរួច គេបែរមុខងាកចេញទៅម្ខាង ដើម្បីកុំអោយសោភិនី និងបូរិនឃើញ តែបូរិន និងសោភិនី បានឃើញមុននេះទៅហើយ ។ យុវស្វាមីភិរិយាដើរកាន់ដៃគ្នាសម្លឹងមើលទៅណាស៊ីដែលឈរទ្រឹងនៅមួយកន្លែង ហើយសោភិនីក៏សើចពេបជ្រាយសម្លឹតសម្លក់ទ្រង់ចំអកអោយ ។

បូរិន និងសោភិនី ឡើងរថយន្តបើកចេញទៅហើយ ណាស៊ីលែងមានសេចក្ដីសុខ មុខដែលស្រស់ញញឹមប្រិមប្រិយអម្បាញមិញក៏ប្រែជាក្រៀមស្រពោន ភ្នក់ភ្លើងស្នេហ៍ដែលរលត់បាត់ និងសំរែកអតីតកាលដ៏ឈឺចាប់ ! ក៏ឆាបឆេះពុះកញ្ជ្រោលក្នុងអារម្មណ៍គេម្ដងទៀត ÷

- មានរឿងអីកើតឡើងឬអូននី ? ហើយអាគាត់នេះវាជាអ្នកណា ?

- ខ្ញុំមិនដែលស្គាល់ទេបង មិនដឹងមកពីណាផង ។ ស្រាប់តែមកឡូឡាដាក់ខ្ញុំ !

- យីអាក្របីព្រៃ ! ឯងមកពីណាក៏ហ៊ានសំដីខែងម្លេះនេះជាប្រពន្ធរបស់អញណា បើឯងចង់និយាយសំដីបៀបនេះ ត្រូវឯងទៅរកកន្លែង

និយាយជាមួយស្រីផ្សេងទៀតទៅ ឬមួយក៏អាឯងឆ្កួត ? បើថាវាឆ្កួតអញនឹងដាក់ឡានបញ្ជូនទៅព្រែកត្នោត ........ ឆ្លើយ !

ឈឺចាប់ណាស់ ! ណាស៊ីយកដៃអង្អែលថ្ពាម ស្ដាបឆ្អឹងជំនី សំដីទ្រគោះបោះបោក កាយវិការព្រៃផ្សៃរបស់លោកភូឈួយខេត្តប៉ូរិន រំលោភលើរាងកាយគេពីថ្ងៃមុនរៀបការសោភិនី ហាក់ដូចជានៅថ្មីៗ ។ មុខលែងស្រស់ ! ដើរលេងលែងសប្បាយ ទីបំផុតណាស៊ីក៏បបួលខ្ញុំត្រឡប់មកផ្ទះវិញ ។

.........................................................................

ការប្រឡងប្រជែង យកមធ្យមសិក្សាប័ត្រ បានប្រព្រឹត្តទៅយ៉ាងក្រៀមក្រំសំរាប់រូបណាស៊ី ។

ក្រោយពីដឹងដំណឹងប្រឡងជាប់ធ្លាក់ហើយ យើងទាំងពីរនាក់ក៏ធ្វើដំណើរត្រឡប់ទៅសៀមរាបវិញ ។ មីងមឿននៅផ្ទះឯណោះ គាត់ខំដុតធូបបន់ស្រន់ សែនមាន់សែនទាដល់វត្ថុសក្ដិសិទ្ធិទាំងឡាយ អោយជួយឃុំគ្រងថែរក្សាណាស៊ីសូមអោយបានប្រឡងជាប់ដូចសេចក្ដីប្រាថ្នា ។

នៅពេលដែលណាស៊ីឡើងទៅដល់លើផ្ទះ មីងមឿនស្ទុះត្រហេប-ត្រហបចេញពីផ្ទះបាយមកទទួលកូន ជាបឋមគាត់ក៏សួរទៅណាស៊ីទាំងភ័យអរថា ÷

- ម៉េចទៅណាស៊ី ! កូនប្រឡងជាប់ទេ ........ !

ណាស៊ី មិនឆ្លើយតបនឹងសំណួរម្ដាយ គេគ្រាន់តែគ្រវីក្បាលដោយទឹកមុខក្រៀមក្រោះ រួចហើយក៏បោះវ៉ាលីសដាក់ខោអាវទៅលើគ្រែ មីងមឿនកាត់យល់ភ្លាម ថាកូនគាត់ច្បាស់ជាប្រឡងធ្លាក់ ។



- ណាស៊ីកូនប្រឡងធ្លាក់ឬ ?

- បាទម៉ែ ....... (ណាស៊ីឆ្លើយព្រមជាមួយគ្នាទឹកភ្នែកក៏ហូរហៀរមក) ខ្ញុំប្រឡងធ្លាក់ ...... ។

ដូចកាំរន្ទះទាំងប្រាំពីរបាញ់ចំកណ្ដាលដើមទ្រូង ។ មីងមឿនរសេះរសោះដៃជើង, ត្រចៀកឡើងហ៊ឹង, ភ្នែកស្រវាំងបែកអំពិលអំពែក, សេចក្ដីសង្ឃឹមរបស់គាត់បានត្រូវរលាយអស់ហើយ ។ អ្នកមីងមេម៉ាយ យំហ៊ូចេញមកដូចកូនក្មេង គាត់ស្ទុះទៅឱបកូនសម្លាញ់ យកមុខទៅនន្ទាក់ននាលលើស្មាទូញ ង៉ក់ ! ង៉ក់ ! យ៉ាងគួរអោយវេទនាភ្នែក ។ ណាស៊ីកូនគាត់ប្រឡងធ្លាក់ គាត់យល់ច្បាស់ណាស់ ថាគ្មានអ្វីក្រៅពីរឿងស្នេហាចាស់នោះទេ ។

- ណាស៊ីកូន ....... ! សេចក្ដីសង្ឃឹមរបស់យើងបានត្រូវផុតតែត្រឹមណេះហើយ ........ ពីថ្ងៃនេះទៅ កូនត្រូវបំភ្លេចរឿងចាស់ចោលចេញ កូនត្រូវខំរៀនសូត្រអោយអស់ពីដួងចិត្ត ម្ដាយសង្ឃឹមថាកូននឹងប្រឡងជាប់នៅឆ្នាំក្រោយជាពុំខាន ........ ។

- ជាតិនេះហួសហើយ ការរៀនសូត្រសំរាប់ខ្ញុំម៉ែ ......... ខ្ញុំធ្វើឱ្យម៉ែពិបាកចិត្តគ្រប់ពេលវេលា ខ្ញុំជាកូនអកតញ្ញូ ! អោយខ្ញុំរៀនតទៅទៀតម្ដេចនឹងកើតម៉ែ ........ ខ្ញុំខ្មាសគេណាស់ ពីថ្ងៃនេះទៅខ្ញុំសូមលាម៉ែទៅជ្រកក្រោមសំពត់កាសាវពស្ត្រហើយ មានតែម្លប់សាសនាទេ អាចរម្ងាប់ដួងចិត្តខ្ញុំអោយស្ថិតនៅក្នុងសភាពស្ងប់ស្ងាត់ លែងរវើរវាយ កាត់ដាច់ពីកាមកិលេសទាំងពួង សូមម៉ែអនុញ្ញាតបំពេញនូវគោលបំណងរបស់ខ្ញុំម្ដងទៀតចុះ ខ្ញុំតាំងចិត្តរួចជាស្រេច ថានឹងចូលបួសរហូតអស់មួយជីវិត ។

មីងមឿន ស្ដាប់វាចាកូនសម្លាញ់ គាត់រិតតែក្ដុកក្ដួលអួលណែន ដូចជាគេយកដុំដែកកំពុងក្ដៅ មកចាក់រោលដើមទ្រូងគាត់ឱ្យក្ដៅផ្សាយ៉ាងសែនសាហ័ស ។ ត្រួយពន្លកសង្ឃឹមជាកេរ្ដិ៍មត៌កសំណល់ពីខ្មោចប្ដីចែកទុកឱ្យគាត់ ក៏មានតែរូបណាស៊ីនេះឯង ចុះបើណាស៊ីបួសទៅទៀត តើអោយគាត់សង្ឃឹមទៅលើអ្នកណា ។

- ណាស៊ីកូនមាសម្ដាយ ......... ! ខ្មោចព្រាយបិសាចអ្វីមកចូលសណ្ឋិតក្នុងខ្លួនកូន បានជាកូនប្រែចិត្តវិបល្លាសយ៉ាងដូច្នេះ ! ម្ដាយសព្វថ្ងៃរស់នៅបាន ដោយសារតែសង្ឃឹមលើកូនមួយទេ ចុះបើកូនរត់ចោលម៉ែទៅបួសទៀត តើអោយម្ដាយរស់នៅជាមួយអ្នកណា ....... !

និយាយរួច មីងមឿនក៏តាំងអង្គុយយំហ៊ូ ! ហ៊ូ ! នឹកតូចចិត្តនឹងវាសនារបស់គាត់ ។

- ឈប់យំទៅម៉ែ ....... ជាតិនេះសេចក្ដីសង្ឃឹមរបស់ខ្ញុំទាំងប៉ុន្មានវារលាយអស់ទៅហើយ ចូរម៉ែឈប់យំសោកហើយគិតថា ណាស៊ីកូនរបស់ម៉ែវាបានស្លាប់បាត់ពីលោកនេះទៅហើយ ....... តែម៉ែនឹងមានកូនមួយទៀតប្រកបទៅដោយគុណសម្បត្តិ និងវិជ្ជាសម្បត្តិ គឺសំណាងមិត្តរបស់ខ្ញុំសំណាងគេប្រឡងជាប់ គេជាកូនកំព្រាគ្មានម្ដាយឪពុកឯណាទេ សព្វថ្ងៃគេយកអារាមធ្វើជាទីជម្រក ខ្ញុំបាននិយាយរឿងរ៉ាវប្រាប់គេអស់ហើយ គេថានឹងមកសុំម៉ែធ្វើជាម៉ែរបស់គេ ហើយនឹងមកនៅថែរក្សាម៉ែកាលបើអត់ពីខ្ញុំទៅ ....... ។

- ណាស៊ីកូន តើមានម្ដាយក្នុងលោកណាអាចស្រលាញ់កូនគេ



អ្នកក្រៅ ផ្ទឹមស្មើនឹងកូនរបស់ខ្លួនទេ ? ទោះបីអាក្រក់ល្អ ឥ. ខ្វាក់. ខ្វិន. ថ្លង់ឆ្កួតលីលា ក៏ជាកូនចេញពីឧទ្ទររបស់ម្ដាយដែរ ...... ម្ដាយសូមអង្វរចិត្តកូនសូមកូនកុំទៅបួសចោលម្ដាយអី ....... ។

- កុំឃាត់ខ្ញុំម៉ែ បើម៉ែមិនអោយខ្ញុំទៅបួសទេ ខ្ញុំប្រាកដជាប្រេះទ្រូងស្លាប់ចោលម៉ែនៅពេលឆាប់ៗ នេះជាពុំខាន ....... ។

និយាយហើយ ណាស៊ីក៏ដើរទៅប្រាសខ្លួនដេកលើគ្រែសន្ធឹងសន្ធៃទាំងសំលៀកបំពាក់ ។ មីងមឿនឆ្អែតចិត្ត ទាល់ប្រាជ្ញា មិនដឹងជារកកលវិធីណានឹងពន្យល់កូន អោយបោះបង់គំនិតនេះចោលចេញ ។

មួយខែកន្លងមកទៀត ដោយការសម្រេចចិត្តដ៏មុតមាំរបស់ណាស៊ី មីងមឿនក៏យល់ព្រមអោយបួស ។ អ្នកមីងមេម៉ាយបានទិញសំពត់ស្បង់ ត្រៃចីវរ និងប្រដាប់ប្រដាសំរាប់សមណសង្ឃឯទៀតជាច្រើន ។ គាត់តាំងចិត្តនឹងធ្វើពិធីបំបួសខ្វាន់នាគណាស៊ី អោយអធឹកអធម្មជាឧឡារិក អោយសមនឹងកូនគាត់មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ ដូច្នេះហើយព្រឹកថ្ងៃស្អែកឡើងគេឃើញមានលោកអាចារ្យ និងភ្ញៀវចាស់ទុំជិតខាងជាច្រើន ចូលមកជួយរួបរួមក្នុងពិធីបំបួសខ្វាន់នាគនៅផ្ទះមីងមឿនយ៉ាងកុះករ ។

កូននាគ ពោលគឺណាស៊ី អង្គុយអោយលោកអាចារ្យកោរសក់កោររោមចិញ្ចើម ដោយទឹកមុខញញឹមស្ងួត ។ បន្ទាប់ពីកោររួចហើយ គេក៏អោយកូននាគទៅងូតទឹកជំរះរាងកាយអោយស្អាតបាត ។ តាមប្រពៃណីខ្មែរយើង មុននឹងបំបួសកូនចៅអោយទៅជាព្រះភិក្ខុសាមណេរ គេត្រូវអោយកូននាគដើរទៅសុំខមាទោសពីបងប្អូន ញាតិសន្ដានជិតឆ្ងាយ ចំពោះអំពើខ្លួន

ដែលបានប្រព្រឹត្តខុសពីថ្ងៃមុន ដោយចេតនាក្តីអចេតនាក្តី សូមអោយរួចរាល់គ្នាតែត្រឹមណោះ ។

ម៉ោងបីរសៀល ពិធីដង្ហែខ្លាន់នាគទៅកាន់វត្តព្រះព្រហ្មរតន៍ក៏ចាប់ផ្តើមធ្វើឡើង គេអោយកូននាគឡើងជិះសេះ ដោយមានចាស់១ ពីរនាក់ជាអ្នកនាំមុខពាជី ។ ខណៈដែលក្បួនដង្ហែរៀបនឹងចេញដំណើរទៅហើយ ព្រឹត្តិការណ៍ចម្លែកដែលគ្មានអ្នកណានឹកស្មានថានឹងកើតមានឡើង ក៏ស្រាប់តែ .....

- អូយ ! ខ្ញុំវិលមុខណាស់ម៉ែ ...... !

ចាំបានតែប៉ុណ្ណោះ ណាស៊ី ឬ កូននាគក៏រមៀលធ្លាក់ពីលើខ្នងពាជី សន្លប់បាត់ស្មារតីមួយរំពេច ។ ការចលាចលផ្អើលឆោឡោក៏មានឡើង មីងមឿនស្រែកភ្លាត់សម្លេងតក់ស្លុតនឹងកូន ÷

- លោកអើយ ! កូនខ្ញុំយ៉ាងម៉េចទៅហើយ ជួយមើលខ្ញុំផង !

ខ្ញុំ និងចាស់១ បីបួននាក់ នាំគ្នាគ្រាហ៍ណាស៊ីឡើងទៅលើផ្ទះជាបន្ទាន់ ដោយយល់ថាណាស៊ីខ្យល់គ ខ្លះក៏ខាំកែងជើង ខ្លះកោសរូតខ្នង ខ្លះរត់ទៅអញ្ជើញពេទ្យហ្មអោយមកព្យាបាលច្រវាត់ច្រវែង ។

មួយសន្ទុះធំមក ណាស៊ីក៏ដឹងខ្លួនតិច១ ឡើងវិញ ហើយចេះតែស្រែកទាររកទឹក ។ ពិធីបំបួសខ្លាន់នាគក៏ត្រូវឈប់ផ្អាកត្រឹមណោះសិន ទំរាំថ្ងៃណា ណាស៊ីបានស្រួលបួលនឹងគិតផ្តើមធ្វើតទៅទៀត ។

# ១០

## ជំងឺរាំរ៉ៃ

ក្តួតឈាមក្រៀមស្ងួតខ្សំុយជីវ៉ា ព្រោះគូសង្សារចិត្តមិនត្រង់
បានថ្មីក្រឡេះចាស់បោះបង់ នេះកែវន្ទួនល្អងឃើញបងក្រ ។
មិនថ្វីទេអូនរូបបងស្លាប់ ជាតិក្រោយសុំចាប់ភពបវរ
ស្មាលាចិត្តខ្មៅមាត់លោបស្គរ ខ្លាចហើយស្រីល្អសតែសាច់ ។

តាំងពីថ្ងៃណាស៊ីធ្លាក់ពីលើខ្នងសេះមក គេក៏ទៅជាមានជំងឺមួយប្រចាំកាយ គឺជម្ងឺរាំរ៉ៃ ។ មីងមឿនភ័យខ្លាចកូនស្លាប់ណាស់ គាត់បានទៅអញ្ជើញគ្រូពេទ្យ និងគ្រូខ្មែរ ដែលធ្លាប់មានល្បីឈ្មោះក្នុងការមើលជំងឺ មកព្យាបាលអោយកូនគាត់ជារៀងរាល់ថ្ងៃ ។ តែ ...... ទោះជាគ្រូហ្មទាំងនោះខំពិនិត្យរោគ ព្យាបាលជំងឺដោយអស់សមត្ថភាពខ្លួនក៏ដោយ ក៏ជំងឺរបស់ណាស៊ីមិនបានជា ឬធូរស្រួលសូម្បីបន្តិចបន្តួចឡើយ កាន់តែយូរថ្ងៃ ក៏កាន់តែធ្ងន់ឡើងជាលំដាប់ដែរ ។

ឃើញទេវង្សរិទ្ធិ ! គ្រោះកំណាចនៃព្រហ្មលិខិតដាក់ទុក្ខទោសលើគ្រួសារមីងមឿនគ្រប់ពេលវេលា ប្តីស្លាប់, ធ្លាក់ខ្លួនក្រ, កូនប្រឡងមិនជាប់, ហើយឥឡូវមកទទួលមានជំងឺទៀត ។ ជីវិតសត្វលោកដែលកើតមានរូបរាងឡើងនៅលើវាលវដ្តសង្សារ សុទ្ធតែជារបស់អនត្តាទាំងអស់ ។ រកកំណត់រក

ជឿអោយទៀងទាត់មិនបានឡើយ ....... កើត. រស់. ស្លាប់. ទុក្ខ. សប្បាយ. គឺជាសំណែននៃព្រះព្រហ្មលិខិតតែម្យ៉ាង ។

មួយខែបានកន្លងផុតទៅ ជំងឺណាស៊ីក៏កាន់តែដុនដាបប្រៀបដូចទូកធ្លាយទឹកចូល ចេះតែស្រឹម១ ទៅរង់ចាំតែពេលវេលានឹងលិចបាត់កប់ទៅក្នុងបាតទន្លេ។ ប្រាក់ក៏អស់ ស្រែពីរបីលក់បញ្ចាំគ្មានសល់ កូននៅតែឈឺដដែលមឹងមឿនអស់បើគិត យំលែងចេញ ទឹកភ្នែករីងខះ គាត់បែរជាសើច ហើយជូនកាលក៏ស្រាប់តែក្រោកឈរច្រៀងផ្តេសផ្តាសដូចវិកលចរិត នេះហើយទឹកចិត្តមាតាស្នេហាររាំងបុត្រ ។

ល្ងាចថ្ងៃមួយ ពូឈឺនញាតិជិតខាងផ្ទះ ដែលមកកំដរជំងឺដែរហៅខ្ញុំទៅពិគ្រោះជាមួយគាត់ស្ងាត់១ កំបាំងពីភ្នែកគេឯង តែពីរនាក់ថា ÷

- ក្មួយសំណាង ........ ! ជំងឺក្មួយណាស៊ុនេះពូគ្មានសង្ឃឹមថានឹងជាទេ មនុស្សកើតទុក្ខ ក្រៀមក្រំឈាមកកក្នុងទ្រូង ពេលក្អួតធ្លាក់ឈាមទាំងដុំ១ ក្នុងដប់ភាគសង្ឃឹមរស់តែពីរភាគប៉ុណ្ណោះ បើតាមយោបល់ពូ ថាយើងគួរតែជួលឡានតូចដឹកក្មួយណាស៊ុ ទៅព្យាបាលខ្លួននៅពេទ្យមិត្តភាពខ្មែរ-សូវៀតឯភ្នំពេញប្រហែលជាមានសង្ឃឹមរស់ខ្លះ ។

ខ្ញុំអង្គុយគិតបន្តិចមក ក៏ឆ្លើយទៅវិញ ÷

- មែនហើយពូ បើយើងនៅតែបណ្តែតបណ្តោយតទៅទៀតមិនកើតទេ ថ្ងៃនេះគ្រាន់តែក្អួតឈាមបីបួនដង តែថាមុននឹងយើងដឹកទៅ ត្រូវទៅសួរណាស៊ុសិន តើគ្នាអាចមានកំលាំងទៅបានទេ ពីព្រោះស្គមសល់តែស្បែកដណ្តប់ឆ្អឹងឥចឹង ដឹកឡានទៅផ្លូវឆ្ងាយវាមានគ្រោះថ្នាក់ច្រើនណាស់ ។



ក្រោយពីអង្គុយគិតយ៉ាងយូរមូលមតិគ្នា ខ្ញុំនិងពូឈឺនក៏មកកន្លែងគ្រែណាស៊ុដេកឈឺ ហើយខ្ញុំបានសួរទៅគេដោយសម្លេងតិច១ ÷

- ណាស៊ុ ...... ខ្ញុំគិតគ្នារួចទៅហើយ ថានឹងជួលឡានតូចដឹកមិត្តទៅព្យាបាលខ្លួនឯភ្នំពេញ តើក្នុងខ្លួនមិត្តមានកម្លាំងអាចធន់ទៅរួចទេ ......

ណាស៊ុចាប់ដៃខ្ញុំជាប់ គេគ្រវីក្បាលមួយ១ ដោយបន្លឺវាចាខ្សាវ១ថា ÷

- អត់អំពើទេសំណាង ........ កុំដឹកខ្ញុំយកទៅណាទៀត .....បណ្តោយអោយខ្ញុំស្លាប់ក្រោមដំបូលផ្ទះនេះចុះ បើមិត្តដឹកខ្ញុំទៅខ្ញុំមុខជាស្លាប់តាមផ្លូវជាមិនខាន ខ្ញុំមិន ........

ណាស៊ុចង់និយាយតទៅទៀត តែគេហត់ណាស់ ដកដង្ហើមលាន់ឃូ ! ឃូ ! ហើយក៏ក្អួតចេញឈាម ខ្ញុំបែរយកកន្ថោរមិនទាន់ ក៏យកដៃទាំងពីរទៅត្រង ។ លោហិតស្រស់១ ធ្លាក់ពេញដៃខ្ញុំ ហើយខ្ទាតមកប្រឡាក់អាវក្រហមច្រាល ។

កាលបើណាស៊ុបាត់ហត់ លែងក្អួត គេក៏ខំប្រឹងបែរមុខមកនិយាយជាមួយខ្ញុំម្តងទៀត ÷

- សំណាង ..... ! ដៃមិត្តប្រឡាក់អស់ហើយ អាវក៏ប្រឡាក់សុទ្ធតែឈាម ទៅរកទឹកលាងទៅ ........

- មិនអីទេណាស៊ុ ចាំបន្តិចខ្ញុំទៅលាងក៏បានដែរ ឥឡូវមិត្តញុំាបបរបន្តិចទៅណា ខ្ញុំនឹងទៅដួសមកបញ្ចុក ......

ណាស៊ុប្រញាប់រាដៃមកខ្ញុំវិញ ÷

- កុំអីសំណាង ....... ខ្ញុំនៅមិនទាន់ឃ្លានទេ ម៉ែខ្ញុំគាត់ទៅណាហើយ ........ ម៉េចមិនឃើញ .......

- អ្នកមីងគាត់អញ្ជើញទៅរកគ្រូមកព្យាបាលមិត្តណា ........ បន្តិចទៀតគាត់នឹងមកវិញហើយ ។

- ទៅរកគ្រូមកមើលខ្ញុំ ? ហ៊ឺ ..... ! អត់ប្រយោជន៍ទេ ខ្ញុំដឹងខ្លួនឯងច្បាស់ ........ ថាខ្ញុំប្រាកដជាស្លាប់ ! បើអត់ពីខ្ញុំទៅ ចូរសំណាងឯងមកនៅផ្ទះខ្ញុំធ្វើកូនគាត់ ហើយជួយថែរក្សាគាត់ផង .......

ពួសដីដ៏សែនអាណោចអាធម្មរបស់ណាស៊ី ធ្វើអោយខ្ញុំរកទប់ទឹកភ្នែកមិនបាន តែខ្ញុំខំនិយាយលួងលោមគេទៅវិញ ÷

- ជំងឺរបស់មិត្តមិនដល់ស្លាប់ទេ ចូរមិត្តតាំងចិត្តអោយក្លាហានឡើង បីបួនថ្ងៃទៀតមិត្តមុខជាជាមិនខាន ។

ណាស៊ី ប្រឹងសើចទាំងបបូរមាត់ស្ងួតក្រៀម ÷

- កុំបាច់មកនិយាយលើកទឹកចិត្តខ្ញុំសំណាង ខ្ញុំដឹងខ្លួនឯងអស់ទៅហើយ .........

ណាស៊ីនិយាយរួច ក៏ឈប់ស្ងៀមដោយហត់ខ្លាំងពេក បន្ទាប់មកភ្នែកគេបិទជិត ហើយក៏សម្ងំលក់ទៅ ។

មួយខែ .... ពីរខែ ........ បីខែ ....... ជំងឺណាស៊ីកាន់តែធុនដាបខ្លាំងឡើងៗ សេចក្តីសង្ឃឹមរបស់ញាតិជិតខាង និងមីងមឿន. ខ្ញុំ ថាណាស៊ីនឹងបានជាក៏ត្រូវរលាយអស់រលីង យើងរាល់គ្នាដឹងជាក់ក្នុងចិត្តថា ណាស៊ីមុខជានឹងលាចាកយើងរាល់គ្នាទៅកាន់បរលោកនាយនៅពេលឆាប់ៗ ខាងមុខនេះជាពិត



ប្រាកដ ។

ថ្ងៃនេះ អាការរោគរបស់ណាស៊ី មានសភាពធ្ងន់ធ្ងរប្លែកជាងសព្វដង ហត់កាន់តែខ្លាំង ភ្នែកឡើងខៀវល្អក់ហើយចេះតែរវើរវាយស្រែកហៅរកឈ្មោះ សោភិនីមិនដាច់ពីមាត់ ÷

- សោភិនី ..... ! សោភិនី ..... ! អូននៅឯណា សោភិនីបងដាច់ខ្យល់ស្លាប់ឥឡូវហើយ អូនចូលមកជិតបងបន្តិចមក ....... សោភិនី .......

មីងមឿន អាណិតកូន គាត់ស្រែកទ្រហោយំក្តែងៗ ពេញផ្ទះញាតិជិតខាងឃើញដូច្នោះក៏នាំគាត់ទៅនៅផ្ទះពូឈីន ដើម្បីកុំអោយសម្លេងយំសោកនេះ ឮទៅដល់ត្រចៀកអ្នកជំងឺ ។ ពេលនោះណាស៊ីកាន់តែដង្ហក់ស្លួឈាមខ្លាំងឡើង ខ្ញុំប្រញាប់ស្ទុះទៅត្រកងខ្លួនណាស៊ីដាក់លើភ្លៅខ្ញុំ អ្នកជំងឺដឹងខ្លួនក៏ស្រែករកសោភិនីទៀត ÷

- អូនសោភិនី ..... ! អូននៅឯណា មកជិតបងបន្តិចមកអូន ......ឱ ប្រហែលជាអូនខ្លាចប្តីអូនទេដឹងហ៊ឺ ! ហ៊ឺ ..... ! អូន .... សោ ..... ភិ ... នី ..

- ខ្ញុំអោយគេទៅតាមសោភិនីមកហើយ ចូរឯងខំសម្ងំទៅណាស៊ី

- អ្នកណាហ្នឹង ....... សំណាងឬ ម៉ែខ្ញុំទៅណាហើយសំណាង ឯណាម៉ែខ្ញុំ ........

- អ្នកមីងគាត់ទៅរកថ្នាំអោយឯងផឹក បីបួនថ្ងៃទៀតឯងមុខជាជាហើយ ខំប្រឹងតាំងចិត្តអោយល្អណាមិត្តណា .......

- ទៅតាមគាត់មក កុំអោយរកថ្នាំអោយខ្ញុំអី ខ្ញុំក្តៅទ្រូងណាស់បន្តិចទៀតខ្ញុំនឹងស្លាប់ហើយ បើមុននឹងស្លាប់អោយខ្ញុំបានឃើញមុខម្តាយខ្ញុំផង ....... ម៉ែ ........ នៅឯណាម៉ែ .......

ពូឈិនដឹងថាណាស៊ីនឹងផុតខ្យល់នៅពេលខាងមុខនេះហើយ គាត់ក៏រត់ទៅតាមយកមីងមឿនមកវិញ ។

មកដល់ជិតកូន មីងមឿនខំជូតទឹកភ្នែកអោយស្អាត រួចប្រឹងនិយាយទៅកូនថា ÷

- ម៉ែមកជិតឯងហើយកូន ........

- ឱ ....... ម៉ែមកហើយឬ (ណាស៊ីយកដៃម្តាយមកដាក់លើទ្រូង) ម៉ែ ..... ! ជាតិនេះខ្ញុំធ្វើបាបម៉ែច្រើនណាស់ សូមម៉ែលើកទោសអោយខ្ញុំផងកូនដាច់ខ្យល់ស្លាប់ចោលម៉ែឥឡូវហើយ ....... ។

មីងមឿនស្រក់ទឹកភ្នែកច្រោក គាត់ខំប្រឹងនិយាយអួល១ ដើមកទៅកាន់កូន ÷

- ម្តាយលើកទោសអោយកូនទាំងអស់ សូមកូនកុំព្រួយអី ។

ណាស៊ីញញឹម ទឹកភ្នែកក៏ហូរហៀរចេញមក ។

- ម៉ែលើកទោសអោយកូនហើយឬ សំណាង ...... ចូរមិត្តអត់ពីខ្ញុំទៅ ជួយថែរក្សាម្តាយខ្ញុំផងណា៎ ..... ខ្ញុំគ្មានសង្ឃឹមមិត្តភក្តិឯណាក្រៅពីសំណាងឯងទេ ។

- ឈប់ព្រួយបារម្ភទៅណាស៊ី ខ្ញុំនឹងប្រតិបត្តិតាមបណ្តាំមិត្តគ្រប់យ៉ាង ........ ។

- សោភិនី ...... ជាតិនេះខ្ញុំសូមលាហើយពិភពស្នេហា សំណាង ! ចូរឯងប្រាប់មិត្តយើងគ្រប់១ គ្នា កុំអោយយកគម្រាប់អាក្រក់តាមខ្ញុំ .... ខ្ញុំស្លាប់ខ្លួនព្រោះស្នេហា ព្រោះស្រិចិត្តក្បត់ កុំអោយយុវជន យុវនារីជាន់ក្រោយយកគំរូតាមខ្ញុំ និងសោភិនីអោយសោះ ចាំអោយច្បាស់ថាស្ត្រីជាសត្រូវ



ក្នុងការសិក្សា ........ ដល់ខ្ញុំស្លាប់ទៅ សូមមិត្តយកឆ្អឹងខ្ញុំទៅដំកល់ទុកក្នុងចេតិយវត្តអង្គរណា៎ ........

ណាស៊ីឈប់និយាយ ផ្តើមហត់ខ្លាំងម្តងទៀត គេដកចង្កាមាន់បញ្ឈរភ្នែក ស្លេស្មឡើងកព្ជសូរគ្រូក១ ខ្ញុំដឹងថា ណាស៊ីមុខជាផុតដង្ហើមលើដៃខ្ញុំ ១ ក៏ឱនខ្សិបដាក់ត្រចៀកគេអោយទន្ទេញធម៌ ÷

- ណាស៊ីតាំងស្មារតីអោយរឹងប៉ឹងណា ឯងកុំគិតរវើរវាយទៅណាអោយសោះ ទន្ទេញធម៌តាមខ្ញុំភ្លាមទៅ ពុទ្ធោអរហំ ! ពុទ្ធោអរហំ !

- ពុទ្ធោអរហំ ......... ! ពុទ្ធោ ....... អ .....រ ..... ហំ ........

ថាបានតែពីរចប់ ណាស៊ីក៏ទន់ក្បាលរងៀក ភ្នែកគេសន្សឹមបិទបន្តិចម្តង១ រហូតជិតស្និទ្ធ វិញ្ញាណក្ខន្ធហោះហើរចេញពីរាងកាយទៅកាន់សុគតិភពហើយ ។ គួរអោយអាសូរមីងមឿនណាស់ គាត់ស្មានថាកូនសម្ងំដេកលក់ពុំបានដឹងថាណាស៊ីផុតខ្យល់ឡើយ អ្នកមីងរៀបក្រោកដើរចេញគាត់និយាយមកខ្ញុំថា ÷

- ដាក់ណាស៊ីចុះអោយដេកស្រួលបួលទៅក្មួយសំណាង កូនខ្ញុំវាអស់កម្លាំងសម្ងំដេកហើយ ។

សែនរំជួលក្នុងចិត្តក្រៃលែង ទ្រាំពុំបានខ្ញុំក៏ជំរាបការពិតដល់គាត់ ÷

- ណាស៊ីផុតខ្យល់អម្បាញមិញ ....... ទៅហើយអ្នកមីង

- អូ ! កូនខ្ញុំស្លាប់ទៅហើយ ! មីងមឿនស្ទុះមកឱបសព យំននាក់ននាល គក់ទ្រូងខ្លួនឯងលាន់សូរ ភឹប ! ភឹប ! ហើយនិយាយរៀបរាប់តាមតែចិត្តគាត់នឹកឃើញ "ណាស៊ី ! ម្តេចក៏អាយុកូនខ្លីម្ល៉េះ អំមិញកូននិយាយរកម្តាយ ឥឡូវម្តេចក៏បែរជាស្លាប់ទៅវិញ ពុទ្ធោ ! ពុទ្ធោ ! មចុរាជ ...... អ្នក

ក៏មានចិត្តកាចសាហាវខ្លាំងម្ល៉េះ  បើអ្នកយកជីវិតកូនខ្ញុំទៅហើយ ទុកអោយខ្ញុំរស់ធ្វើអ្វីទៀត  មកផ្តាច់ជីវិតខ្ញុំទៅ ! ខ្ញុំមិនចង់រស់នៅព្រាត់ប្រាសកូនចៅដូច្នេះទេ ...... !"

ចាស់ៗ បីបួននាក់  ដែលអង្គុយនៅទីនោះអត់ទ្រាំមើលទិដ្ឋភាពដ៏សែនខ្លោចផ្សានេះពុំបាន  គេក៏ចូលមកនិយាយលួងលោមមីងមឿន  ហើយគ្រាហ៏គាត់ចេញពីទីនោះទៅ ។ បន្ទាប់មក  ខ្ញុំក៏លើកសពទៅដាក់លើគ្រែ រួចយកភួយថ្មីមួយមកគ្របខ្លួនសពតាំងពីចុងជើងរហូតដល់ក្បាល ។

លុះធ្វើក្តារមឈូសរួចហើយ  គេក៏បញ្ចូលសពទៅក្នុងក្តារមូលមតិគ្នាថានឹងដឹកលំទុកពីរថ្ងៃ រង់ចាំញាតិមិត្តដែលនៅទីឆ្ងាយៗ ។

- នេះហើយជារឿងពិត របស់ណាស៊ីមិត្តខ្ញុំណាវង្សរិទ្ធិ ណាស៊ីស្លាប់ក៏ព្រោះតែសោភិនីនេះឯង .... !

សំណាងនិយាយរឿងប្រាប់វង្សរិទ្ធិចប់  ដំណក់ទឹកថ្លាដូចគ្រាប់ពេជ្រពីរដំណក់  ក៏រមៀលចេញពីរង្វង់ភ្នែកគេស្រក់ទៅលើដៃវង្សរិទ្ធិក្តៅឧណ្ហៗ ។

- រឿងរបស់ណាស៊ីនេះកំសត់ណាស់  ចាំទៅដល់ភ្នំពេញវិញ ខ្ញុំនឹងអោយមិត្តម្នាក់ឈ្មោះ ហាក់ ឆៃហុក  គេនិពន្ធជាសៀវភៅប្រលោមលោកមួយដើម្បីទុកជាអនុស្សាវរីយ៍ ឧទ្ទិសដល់វិញ្ញាណក្ខ័ន្ធរបស់អ្នកស្លាប់  នឹងទុកជាក្បូនទូន្មានដល់យុវជន  យុវនារីទូទៅ  កុំអោយប្រព្រឹត្តដូចជារូបណាស៊ី  និងនាងសោភិនីទៀត ។

ក្រោយពីសន្ទនាគ្នា ពីនេះពីនោះបន្តិចទៀតមក សំណាង និងវង្ស-រិទ្ធិ  ក៏នាំគ្នាដើរចេញពីផ្ទះបាយ  ទៅកាន់កន្លែងដឹកលំក្តារមឈូសវិញ ។

# ១១

# ផ្សែងមរណៈ

ខ្ញុំត្រូវគេយកទៅបូជា  ក្រោយព្យុះមរណាបក់កញ្ច្រោក
វិញ្ញាណហើរទៅឋានបរលោក  សល់ក្តីទាបថោកសោកសោកា ។
ភ្លើងឆេះសន្ធោរពោរពុះក្តៅ  ផ្សែងហោះខ្មួលខ្មៅឈើរហាស៍
នេះហើយគេហៅផ្សែងមរណា  ឆាបឆេះកាយាសង្ខារខ្ញុំ ។

ម៉ោង មួយសែសិបប្រាំនាទីហើយ  នៅខ្វះដប់ប្រាំនាទីទៀត នឹងត្រូវដង្ហែក្បួនសពទៅធ្វើឈាបនកិច្ចឯព្រៃប៉ាឆា ។

មីងមឿន  ស្លៀកសពាក់សកាន់ទុក្ខមរណសញ្ញាឱ្យកូន  ចំណែកញាតិសាច់សាលោហិតជិតឆ្ងាយ  និងមិត្តភក្តិរបស់សព  ក៏មានខ្ទាស់ផ្កាំងសំពត់ខ្មៅជាប់នឹងអាវស  ជាសញ្ញាកាន់ទុក្ខគ្រប់ៗ គ្នា ។

ជិតដល់ពេលរង្គិលក្តារមឈូសចេញពីផ្ទះទៅព្រៃប៉ាឆាសមសាន សូរទំនួញដ៏គួរអោយសង្វេកក្នុងដួងចិត្តរបស់ម្តាយនៃសព ដែលបាត់ស្ងាត់អស់រយៈពេលយ៉ាងយូរមកហើយ  ក៏ឮឡើងកន្ទ្រាក់អារម្មណ៍ភ្ញៀវម្តងទៀត ÷

- ឱព្រះជាម្ចាស់នៃសត្វលោកអើយ ........ !  គេរាល់គ្នាប៉ុនរុងនឹងយកកូនខ្ញុំទៅដុតឥឡូវហើយឬ ?  ណាស៊ីកូន !  ម្លេះសមកូនក្តៅនៅក្នុងភ្លក់ភ្លើងយ៉ាងណាទៅ  ពីថ្ងៃនេះម្តាយខានឃើញមុខអ្នកទៀតហើយ  រាងកាយកូននឹងក្លាយទៅធ្យូងផេះ  ទេ !  ទេ ! ខ្ញុំមិនអោយអ្នកណាយកកូនខ្ញុំទៅដុតទេ ដុតខ្ញុំវិញទៅល្អជាង  ខ្ញុំចង់ស្លាប់ជំនួសកូនខ្ញុំ ....... ! ហ៊ឺ ! ហ៊ឺ ! ..... ហ៊ឺ !..

មីងមឿនយំស្រែក  យករូបថតណាស៊ីមកឱបផ្ដប់នឹងដើមទ្រូងគាត់បុកក្បាលទៅនឹងក្តារមឈូសប៉ុង ! ប៉ុង ! ននាក់ននាល  មិនចង់អោយគេ

យកសពកូនគាត់ចេញពីផ្ទះ ។ អ្នកនៅក្បែរទាំងប៉ុន្មានរំជួលក្នុងចិត្ត ធ្វើភ្នែករលីងរលោង ហើយអត់ទ្រាំទប់តទៅទៀតលែងបាន ក៏ស្រក់ទឹកភ្នែកចេញមក យំអណ្ដឹតអណ្ដកគ្រប់ៗ គ្នា ។

បរិយាកាសពេលនេះ ស្ថិតនៅក្នុងសភាពអាប់អួរគេឮតែសូរស្រែកយំទ្រហឹងពេញផ្ទះ អស់មានអ្នកណាជួយលួងលោមអ្នកណាទៀត ហើយម្នាក់ៗអង្គុយយំស្រណោះស្រណោក អាឡោះអាល័យនឹងសពមិនចេះស្រាកស្រាន្ត ។ នៅខាងមុខផ្ទះឯណោះ រថយន្តមែរសីដេស (Mercedes 220 S) ពណ៌ត្រួយចេកមួយលូនមកឈប់មុខផ្ទះមីងមឿន នៅក្នុងរថគេឃើញមានមនុស្សពីរនាក់ គឺប្រុសជាសូហ្វ័រ (chauffeur) និងម្នាក់ទៀត អង្គុយបាំងខាងក្រោយជាសុភាពស្ត្រីរូបស្អាត ។

គ្រាន់តែស្ត្រីនោះចុះពីលើរថយន្តភ្លាម គេក៏អាចដឹងថានាងមានផ្ទៃពោះ ។ សាច់ពោះដែលខ្ទាតចេញពីរាងដ៏ល្វតល្វន់ បញ្ជាក់យ៉ាងច្បាស់ថាយ៉ាងហោចណាស់នាងក៏ទម្ងន់បានបួនប្រាំខែហើយ តើនាងនោះជាអ្នកណាទៅអេះ ? ស្ត្រីផើមឈរសម្លឹងមើលទៅទង់មរណៈដោយដួងចិត្តវិប្បយោគនឹកងឿងឆ្ងល់តែម្នាក់ឯង អ្នកណាស្លាប់ ? ពេលនោះ សំណាងដើរចេញមកក្រៅ ស្ត្រីផើមក្រឡេកឃើញក៏ស្រែកហៅ ÷

- បងសំណាង !

- អូ ! អ្នកសោភិនីទេឬ ?

សោភិនីដើរតម្រង់ទៅសំណាង ព្រមទាំងសួរគេដោយវិតក្កថា ÷

- បងសំណាង ........! អ្នកណាស្លាប់ ?

- ហ៊ឺះ ! (សំណាងសើចចំអកអោយសោភិនី) អ្នកណាស្លាប់ ? មិនជាពិបាកយល់ទេអ្នក ស្ដាប់សូរស្រែកទួញយំលើផ្ទះឯណោះ វាបញ្ជាក់យ៉ាងច្បាស់ណាស់ ថាអ្នកស្លាប់គឺណាស៊ីមិត្តខ្ញុំ !



- បងណាស៊ីស្លាប់ !

- ត្រូវហើយអ្នក ........ អ្នកមកធ្វើអ្វីទៀត គ្រប់យ៉ាងវាបានឆ្លងផុតទៅដល់ទីបញ្ចប់ហើយ .......

សោភិនីមុខឡើងស្លាំងអត់ឈាម នាងរត់ឡើងទៅលើផ្ទះ វែកគេវែកឯង ទៅយំបោកខ្លួននឹងក្ដារមឈូស បណ្ដាញាតិមិត្តសព នាំគ្នាស្រឡាំងកាំងដោយមិនដឹងរឿងហេតុ ។

- បងណាស៊ី (សោភិនីនិយាយ) បងស្លាប់ចោលអូនហើយ ? ....... អូនជាស្រីកាកី ! ស្រីក្លោកមាស ! អាក្រក់ជួរជាតិណាស់ ! អូនដឹងខ្លួនហើយថា បងស្លាប់នេះគឺដោយសារតែរូបអូនម្នាក់ អូនជាស្រីឈ្លក់វង្វេងនឹងទ្រព្យសម្បត្តិមាសពេជ្រ អូនក្បត់ចិត្តបង ..... អូនភ្លេចពាក្យសម្បថ .... ភ្លេចទាំងកូននៅក្នុងផ្ទៃ ដែលបងជាអ្នកអោយកំណើតដល់វាទៀត ? សូមវិញ្ញាណក្ខ័ន្ធដ៏ប្រសើររបស់បងទៅកាន់សុខគតិភពចុះ អូនសូមខមាទោសចំពោះវិញ្ញាណក្ខន្ធបង ...... សូមវិញ្ញាណក្ខន្ធបងអហោសិកម្មអោយអូនផង ។

- គ្រប់យ៉ាងវាហួសអស់ទៅហើយ (សំណាងនិយាយ) សូមអ្នកឈប់យំស្រែកទៅ កុំអោយគេរាល់គ្នារន្ធត់ចិត្តកាន់តែខ្លាំងជាងនេះទៅទៀត បើទោះជាអ្នកខំស្រែកទ្រហោយំទាល់តែបែកក្ដារមឈូសនេះជាពីរបីចំណែក ក៏ណាស៊ីមិត្តខ្ញុំមិនអាចរស់ឡើងវិញដែរ ....... អ្នកជាអ្នកកសាង ហើយខ្លួនអ្នកជាអ្នកបំផ្លាញទៅវិញទេតើ ...... ។

សភាពស្ងប់ស្ងាត់កើតឡើងមួយខណៈ សោភិនីបានទៅក្រាបសំពះអង្វរសុំទោសអ្នកមីងមឿន ហើយនាងសុំស្លៀកសពាក់ស ដើម្បីចូលរួមមរណសញ្ញាដង្ហែសពទៅធ្វើឈាបនកិច្ច ។

លុះដល់ម៉ោងពីរ ក្បួនដង្ហែសពក៏ចាប់ផ្ដើមធ្វើឡើងសម្លេងក្លងខែក (ស្គរសំរាប់ហែខ្មោច) លាន់ឮគ្រលូច ស្រឡៃខំដំអូញសំនៀងរបស់ខ្លួនតូចឆ្មារ ហាក់ដូចជាចង់ឆក់យកដួងព្រលឹងអ្នកទាំងអស់គ្នាអោយបាត់បង់ពីរាងកាយទៅតាមបុគ្គលដែលស្លាប់ ។ នៅតាមផ្លូវទៅកាន់ប៉ាឆា សូរ

សំរែកស្រែកដង្ហោយយំនៃក្រុមគ្រួសារសព លាយឡំនឹងសង្វាក់ស្គរក្លងខែក ដែលក្រុមអ្នកភ្លេងបន្លឺឡើង ទូង ! ទូង ! មិនដាច់រយៈ ។

អនិច្ចា ! សង្ខារមិនទៀងទាត់ កើតហើយរមែងតែងស្លាប់ទៅវិញរៀងរាល់រូប .....អ្វីៗ នៅក្នុងលោកសុទ្ធតែជាអនត្តាទាំងអស់ ។ សពណាស៊ីបុរសកំសត់ បានត្រូវគេសែងក្តារមឈូសទៅដឹកល់លើគំនរឧសក្នុងឈាបនដ្ឋាន ហើយបន្ទាប់មកព្រះអគ្គីក៏ឆាបឆេះបញ្ចេញអណ្តាតភ្លើង សន្ធោរសន្ធៅហុយផ្សែងទ្រលោមខ្មៅខ្ទួលខ្ទាញ់ទៅលើព្ធដ៏អាកាស ឱ ! ........ ផ្សែងមរណៈ !

មីងមឿនឈរសម្លឹងមើលអណ្តាតភ្លើងដែលកំពុងឆេះដង្គោលលេបរូបរាងកាយកូនសម្លាញ់គាត់អោយបាត់ម្តងបន្តិចៗ ពីរង្វង់ចក្ខុ ។ មុខគាត់ឡើងខ្មៅដូចមរណ៍ បេះដូងថ្លើមប្រមាត់ ស្ទើរនឹងប្រេះធ្លាយចេញពីទ្រូងគ្មានពេលណាតក់ស្លុតរំជួលចិត្តដូចជាពេលនេះទេ គាត់ចង់ស្ទុះចូលទៅក្នុងភ្នក់ភ្លើងឱ្យស្លាប់បាត់បង់ជីវិតតាមកូន តែធ្វើម្តេច... បើខ្លួនប្រាណគាត់ ទាំងមូលត្រូវសំណាងឱបជាប់ទៅហើយ ។ សោភិនីពេលនេះនាងក៏មានសភាពមិនខុសពីមីងមឿនដែរ នាងយំស្រែក ដង្ហោយហៅឈ្មោះណាស៊ី ទាល់តែសន្លប់បាត់ស្មារតី ។..............

បីថ្ងៃក្រោយពីរំលាយសពណាស៊ីមក សោភិនីក៏លាមីងមឿន និងសំណាងត្រឡប់ទៅនៅជាមួយប្តីនាងវិញ ដោយសន្យាថានៅពេលណានាងសំរាលបុត្រ នាងនឹងយកកូនមកលេងសៀមរាបម្តងទៀត ។

ចំណែក សំណាង ក៏បានជញ្ជូនឥវ៉ាន់ពីវត្តមកនៅជាមួយមីងមឿន ហើយយកអដ្ឋិធាតុណាស៊ីទៅបញ្ចុះនៅចេតិយវត្តអង្គរតាមបណ្តាំរបស់គេ ។

រឿង ឱ ! ផ្សែងមរណៈ សន្មតថាចប់តែត្រឹមណេះ សូមជោគជ័យសេរីមង្គលមានដល់អស់លោកអ្នកនាងកញ្ញា ដែលបានអានសៀវភៅនេះគ្រប់ៗ គ្នាកុំបីឃ្លាងឃ្លាតឡើយ ។

**ចប់ដោយបរិបូណ៌**

អ្នកនិពន្ធ

**ធោក់ ឆៃធុក**

Khmer Story Lovers